# ច្បាប់ហ្ស៊ឺណែវស្តីពី
# ការចុះបញ្ជីជាអន្តរជាតិនៃគំនូរឧស្សាហកម្ម

### អនុម័តដោយសន្និសីទការទូតនៅថ្ងៃទី ២ ខែ កក្កដា ឆ្នាំ ១៩៩៩

<u>**បទប្បញ្ញត្តិផ្តើម**</u>

- មាត្រា ១ :  ពាក្យបំព្រួញ
- មាត្រា ២ : ការអនុវត្តនូវកិច្ចការពារដទៃទៀតដែលផ្តល់ដោយច្បាប់នៃ
ភាគីហត្ថលេខី និងដោយសន្ធិសញ្ញាអន្តរជាតិមួយចំនួន

<u>**ជំពូកទី១ : សំណុំលិខិតស្នើសុំអន្តរជាតិ និងការចុះបញ្ជីអន្តរជាតិ**</u>

- មាត្រា ៣ : សិទ្ធិដាក់សំណុំលិខិតស្នើសុំអន្តរជាតិ
- មាត្រា ៤ : នីតិវិធីក្នុងការដាក់សំណុំលិខិតស្នើសុំអន្តរជាតិ
- មាត្រា ៥ : ខ្លឹមសារនៃសំណុំលិខិតស្នើសុំអន្តរជាតិ
- មាត្រា ៦ : អាទិភាព
- មាត្រា ៧ : កម្រៃក្នុងការជ្រើសរើស
- មាត្រា ៨ : ការកែតម្រូវកំហុស
- មាត្រា ៩ : កាលបរិច្ឆេទសុំចុះបញ្ជីសំណុំលិខិតស្នើសុំអន្តរជាតិ
- មាត្រា ១០ : ការចុះបញ្ជីអន្តរជាតិ កាលបរិច្ឆេទចុះបញ្ជីអន្តរជាតិ ការចុះផ្សាយ និងច្បាប់ចម្លងជាសំងាត់នៃការចុះបញ្ជីអន្តរជាតិ
- មាត្រា ១១ : ការពន្យារការចុះផ្សាយ
- មាត្រា ១២ : ការបដិសេធ
- មាត្រា ១៣ : លក្ខខណ្ឌពិសេសស្តីអំពីការរួមបញ្ចូលតែមួយនៃគំនូរ
- មាត្រា ១៤ : អានុភាពនៃការចុះបញ្ជីអន្តរជាតិ
- មាត្រា ១៥ : មោឃភាព
- មាត្រា ១៦ : ការកត់ត្រាការផ្លាស់ប្តូរ និងបញ្ហាផ្សេងទៀតស្តីអំពីការចុះបញ្ជីអន្តរជាតិ
- មាត្រា ១៧ : រយៈពេលដំបូង និងការចុះបញ្ជីអន្តរជាតិសារឡើងវិញ និងរយៈពេលនៃកិច្ចការពារ
- មាត្រា ១៨ : ពត៌មានស្តីអំពីការចុះផ្សាយការចុះបញ្ជីអន្តរជាតិ

<u>**ជំពូកទី២ : បទប្បញ្ញត្តិរដ្ឋបាល**</u>

- មាត្រា ១៩ : ការិយាល័យរួមនៃរដ្ឋមួយចំនួន
- មាត្រា ២០ : សមាជិកភាពនៃសហភាពឡាអេ
- មាត្រា ២១ : សន្និបាត
- មាត្រា ២២ : ការិយាល័យអន្តរជាតិ
- មាត្រា ២៣ : ហិរញ្ញវត្ថុ
- មាត្រា ២៤ : បទបញ្ជា

**ជំពូកទី៣ : ការកែប្រែ និងវិសោធនកម្ម**

- មាត្រា ២៥ : ការកែប្រែច្បាប់នេះ
- មាត្រា ២៦ : ការធ្វើវិសោធនកម្មមាត្រាមួយចំនួនដោយសន្និបាត

**ជំពូកទី៤ : អវសានប្បញ្ញត្តិ**

- មាត្រា ២៧ : ការក្លាយជាភាគីនៃច្បាប់នេះ
- មាត្រា ២៨ : កាលបរិច្ឆេទអានុភាពនៃការផ្តល់សច្ចាប័ន និងការចូលជាសមាជិក
- មាត្រា ២៩ : ការហាមឃាត់ចំពោះខដាក់លក្ខខណ្ឌ
- មាត្រា ៣០ : សេចក្តីប្រកាសដែលធ្វើឡើងដោយភាគីហត្ថលេខី
- មាត្រា ៣១ : ការអនុវត្តច្បាប់ឆ្នាំ ១៩៣៤ និងច្បាប់ឆ្នាំ១៩៦០
- មាត្រា ៣២ : ការប្រកាសដកខ្លួនចេញពីច្បាប់នេះ
- មាត្រា ៣៣ : ភាសានៃច្បាប់នេះ  ហត្ថលេខា
- មាត្រា ៣៤ : កន្លែងដាក់តម្កល់

## បទប្បញ្ញត្តិផ្តើម
## មាត្រា ១
## ពាក្យបំព្រួញ

នៅក្នុងន័យនៃច្បាប់នេះ :

(i) “ កិច្ចព្រមព្រៀងទីក្រុងឡាអេ ” មានន័យថា  កិច្ចព្រមព្រៀងក្រុងឡាអេស្តីពីការតម្កល់ជាអន្តរជាតិនៃគំនូរឧស្សាហកម្ម  នឹងត្រូវឱ្យឈ្មោះជាថ្មីថាកិច្ចព្រមព្រៀងទីក្រុងឡាអេស្តីពីការចុះបញ្ជីជាអន្តរជាតិនៃគំនូរឧស្សាហកម្ម ។

(ii) “ ច្បាប់នេះ ”  មានន័យថា កិច្ចព្រមព្រៀងទីក្រុងឡាអេដែលបានបង្កើតឡើងដោយច្បាប់បច្ចុប្បន្ន ។

(iii) “ បទបញ្ជា ” មានន័យថា បទបញ្ជាទាំងឡាយដែលស្ថិតនៅក្រោមច្បាប់នេះ ។

(iv) “ បានកំណត់ ”  មានន័យថាបានកំណត់នៅក្នុងបទបញ្ជា ។

(v) “ អនុសញ្ញាទីក្រុងប៉ារីស ” មានន័យថា អនុសញ្ញាទីក្រុងប៉ារីសស្តីពីកិច្ចការពារកម្មសិទ្ធិឧស្សាហកម្មដែលបានចុះហត្ថលេខានៅទីក្រុងប៉ារីស ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ១៨៨៣ ដូចដែលបានកែប្រែ និងធ្វើវិសោធនកម្មឡើងវិញ ។

(vi) “ ការចុះបញ្ជីអន្តរជាតិ ” មានន័យថា ការចុះបញ្ជីជាអន្តរជាតិនៃគំនូរឧស្សាហកម្មដែលបានធ្វើឡើងស្របតាមច្បាប់នេះ ។

(vii) “ សំណុំលិខិតស្នើសុំអន្តរជាតិ ” មានន័យថា សំណុំលិខិតស្នើសុំដើម្បីចុះបញ្ជីអន្តរជាតិ ។

(viii) “ បញ្ជីអន្តរជាតិ ” មានន័យថា ជាកម្រងទិន្នន័យផ្លូវការស្តីអំពីការចុះបញ្ជីជាអន្តរជាតិ ដែលបានរក្សាទុកដោយការិយាល័យអន្តរជាតិ ហើយទិន្នន័យដែលច្បាប់នេះឬបទបញ្ជាតម្រូវ ឬអនុញ្ញាតឱ្យកត់ត្រាទុក ដោយមិនគិតពីមធ្យោបាយនូវការរក្សាទុកទិន្នន័យនេះឡើយ ។

(ix) “ បុគ្គល ” មានន័យថា រូបវន្តបុគ្គល ឬនីតិបុគ្គល ។

(x) “ អ្នកដាក់ពាក្យសុំ ” មានន័យថា បុគ្គលដែលបានដាក់ឈ្មោះខ្លួននៅក្នុងសំណុំលិខិតស្នើសុំអន្តរជាតិ ។

(xi) “ ម្ចាស់សិទ្ធិ ” មានន័យថា បុគ្គលដែលមានឈ្មោះរបស់ខ្លួនក្នុងការចុះបញ្ជីអន្តរជាតិត្រូវបានកត់ត្រាទុកក្នុងបញ្ជីអន្តរជាតិ ។

(xii) “ អង្គការអន្តររដ្ឋាភិបាល ” មានន័យថា អង្គការអន្តររដ្ឋាភិបាលដែលមានលក្ខណៈគ្រប់គ្រាន់ដើម្បីក្លាយជាភាគីនៃច្បាប់នេះស្របទៅតាមមាត្រា ២៧ (១) (ii) ។

(xiii) “ ភាគីហត្ថលេខី ” មានន័យថា រដ្ឋ ឬអង្គការអន្តររដ្ឋាភិបាលណាមួយ ដែលជាភាគីនៃច្បាប់នេះ ។

(xiv) “ ភាគីហត្ថលេខីរបស់អ្នកដាក់ពាក្យសុំ ” មានន័យថា ភាគីហត្ថលេខី ឬភាគីហត្ថលេខីណាមួយ ដែលអ្នកដាក់ពាក្យសុំបានទទួលសិទ្ធិក្នុងការដាក់សំណុំលិខិតស្នើសុំអន្តរជាតិក្នុងទំនាក់ទំនងជាមួយភាគីហត្ថលេខីនេះ ដោយបានបំពេញយ៉ាងហោចណាស់លក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៣ ។ តាមមាត្រា៣ នៅពេលដែលភាគីហត្ថលេខីពីរឬច្រើន ដែលអ្នកដាក់ពាក្យសុំបានទទួលសិទ្ធិក្នុងការដាក់សំណុំលិខិតស្នើសុំអន្តរជាតិ “ភាគីហត្ថលេខីរបស់អ្នកដាក់ពាក្យសុំ” មានន័យថា ភាគីហត្ថលេខីមួយក្នុងចំណោមភាគីហត្ថលេខីទាំងនេះ ដែលបានបញ្ជាក់ក្នុងសំណុំលិខិតស្នើសុំអន្តរជាតិ ។

(xv) “ ដែនដីនៃភាគីហត្ថលេខី ” មានន័យថានៅពេល ដែលភាគីហត្ថលេខជារដ្ឋគឺដែនដីនៃរដ្ឋនោះ ហើយនៅពេលដែលភាគីហត្ថលេខីជាអង្គការអន្តររដ្ឋាភិបាល គឺដែនដីដែលអនុវត្តសន្ធិសញ្ញាដែលបង្កើតអង្គការអន្តររដ្ឋាភិបាលនេះ ។

(xvi) “ ការិយាល័យ” មានន័យថា ទីភ្នាក់ងារដែលភាគីហត្ថលេខីមួយដាក់ឱ្យទទួលខុសត្រូវក្នុងការផ្តល់កិច្ចការពារគំនូរឧស្សាហកម្មដែលមានអានុភាព នៅក្នុងដែនដីនៃភាគីហត្ថលេខីនេះ ។

(xvii) “ ការិយាល័យត្រួតពិនិត្យ ” មានន័យថា ជាការិយាល័យមួយដែលត្រួតពិនិត្យជាស្វ័យប្រវត្តិនូវសំណុំលិខិតស្នើសុំ ដែលបានដាក់ដើម្បីសុំកិច្ចការពារគំនូរឧស្សាហកម្ម ហើយយ៉ាងហោចណាស់ដើម្បីកំណត់ថា គំនូរឧស្សាហកម្មនេះបានបំពេញលក្ខខណ្ឌថ្មី ។

(xviii) “ ការជ្រើសរើស” មានន័យថា ជាសំណើដើម្បីឱ្យការ ចុះបញ្ជីជាអន្តរជាតិមានអានុភាពនៅក្នុងដែនដីភាគីហត្ថលេខីមួយ ។ ការជ្រើសរើសនេះ ក៏មានន័យផងដែរថាជាការកត់ត្រាទុកនូវសំណើនេះនៅក្នុងបញ្ជីអន្តរជាតិ ។

(xix) “ ភាគីហត្ថលេខីជ្រើសរើស” និង “ការិយាល័យជ្រើសរើស ” មានន័យថា ភាគីហត្ថលេខី និងការិយាល័យនៃភាគីហត្ថលេខី ដែលអនុវត្តការជ្រើសរើសរៀងៗខ្លួន ។

(xx) “ ច្បាប់ឆ្នាំ១៩៣៤ ” មានន័យថា ច្បាប់ដែលបានចុះហត្ថលេខានៅទីក្រុងឡុងដ៍ចុះថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ១៩៣៤ នៃកិច្ចព្រមព្រៀងទីក្រុងឡាអេ ។

(xxi) “ ច្បាប់ឆ្នាំ១៩៦០ ” មានន័យថា ច្បាប់ដែលបានចុះហត្ថលេខានៅទីក្រុងឡាអេចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ១៩៦០ នៃកិច្ចព្រមព្រៀងទីក្រុងឡាអេ ។

(xxii) “ ច្បាប់បន្ថែមឆ្នាំ១៩៦១ ” មានន័យថា ច្បាប់ដែលបានចុះហត្ថលេខានៅទីក្រុងម៉ូណាកូ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ១៩៦១ បន្ថែមលើច្បាប់ឆ្នាំ១៩៣៤ ។

(xxiii) “ ច្បាប់បំពេញបន្ថែមឆ្នាំ១៩៦៧ ” មានន័យថាជាច្បាប់បំពេញបន្ថែម ដែលបានចុះហត្ថលេខានៅទីក្រុងស្តុកហូម ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៦៧ ដែលបានធ្វើវិសោធនកម្ម នៃកិច្ចព្រមព្រៀងទីក្រុងឡាអេ ។

(xxiv) “ សហភាព” មានន័យថា សហភាពឡាអេ ដែលបានបង្កើតឡើងដោយកិច្ចព្រមព្រៀងទីក្រុងឡាអេ ចុះថ្ងៃទី ៦ ខែ វិច្ឆិកា ឆ្នាំ ១៩២៥ និងបានរក្សាដោយច្បាប់ឆ្នាំ ១៩៣៤ និង ១៩៦០ ច្បាប់បន្ថែមឆ្នាំ ១៩៦១ ច្បាប់បំពេញបន្ថែមនៃឆ្នាំ ១៩៦៧ និងច្បាប់នេះ ។

(xxv) “ សន្និបាត ” មានន័យថា សន្និបាតដូចមានចែងនៅក្នុងមាត្រា ២១ (១) (ក) ឬក៏អង្គភាពណាមួយទៀត ដែលជំនួសសន្និបាតនេះ ។

(xxvi) “ អង្គការ ” មានន័យថា អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ។

(xxvii) “ អគ្គនាយក ” មានន័យថា អគ្គនាយករបស់អង្គការ ។

(xxviii) “ ការិយាល័យអន្តរជាតិ ” មានន័យថា ការិយាល័យអន្តរជាតិរបស់អង្គការ ។

(xxix) “លិខិតតុបករណ៍នៃការផ្តល់សច្ចាប័ន” ត្រូវបកស្រាយដោយបញ្ចូលលិខិតតុបករណ៍នៃការទទួលយកឬការយល់ព្រម ។

## មាត្រា២
## ការអនុវត្តនូវកិច្ចការពារដទៃទៀតដែលផ្តល់ដោយច្បាប់នៃភាគីហត្ថលេខី និងដោយសន្ធិសញ្ញាអន្តរជាតិមួយចំនួន

១- [ ច្បាប់របស់ភាគីហត្ថលេខី និងសន្ធិសញ្ញាអន្តរជាតិមួយចំនួន ] បទប្បញ្ញត្តិនៃច្បាប់នេះមិនប៉ះពាល់សំណុំលិខិតស្នើសុំកិច្ចការពារច្រើនជាង ដែលច្បាប់របស់ភាគីហត្ថលេខីមួយអាចផ្តល់ឱ្យ ហើយក៏មិនត្រូវប៉ះពាល់ដល់កិច្ចការពារចំពោះស្នាដៃសិល្បៈនិងស្នាដៃសិល្បៈអនុវត្ត ដែលផ្តល់ឱ្យដោយសន្ធិសញ្ញាអន្តរជាតិ និងអនុសញ្ញាស្តីពីសិទ្ធិអ្នកនិពន្ធ ឬមិនត្រូវប៉ះពាល់កិច្ចការពារ ដែលបានផ្តល់ឱ្យគំនូរឧស្សាហកម្មតាមកិច្ចព្រមព្រៀងស្តីពីទិដ្ឋភាពពាណិជ្ជកម្មទាក់ទងនឹងកម្មសិទ្ធិបញ្ញា ដែលជាឧបសម្ព័ន្ធនៃកិច្ចព្រមព្រៀងស្តីពីការបង្កើតអង្គការពាណិជ្ជកម្មពិភពលោក ។

២- [ កាតព្វកិច្ចដែលត្រូវគោរពតាមអនុសញ្ញាទីក្រុងប៉ារីស ] ភាគីហត្ថលេខីនីមួយៗត្រូវគោរពតាមបទប្បញ្ញត្តិទាំងឡាយនៃអនុសញ្ញាទីក្រុងប៉ារីស ដែលទាក់ទងនឹងគំនូរឧស្សាហកម្ម ។

# ជំពូកទី១
# សំណុំលិខិតស្នើសុំអន្តរជាតិ និង ការចុះបញ្ជីអន្តរជាតិ
## មាត្រា៣
## សិទ្ធិដាក់សំណុំលិខិតស្នើសុំអន្តរជាតិ

បុគ្គលណាមួយដែលជាពលរដ្ឋនៃរដ្ឋដែលជាភាគីហត្ថលេខី ឬក៏ជាពលរដ្ឋនៃរដ្ឋសមាជិកអង្គការអន្តររដ្ឋាភិបាលដែលជាភាគីហត្ថលេខី ឬបុគ្គលដែលមានលំនៅស្ថានមានលំនៅអចិន្ត្រៃយ៍ ឬមានសហគ្រាសពាណិជ្ជកម្មឬឧស្សាហកម្មពិតប្រាកដនិងកំពុងដំណើរការនៅក្នុងដែនដីរបស់ភាគីហត្ថលេខីមួយ ត្រូវមានសិទ្ធិដាក់សំណុំលិខិតស្នើសុំអន្តរជាតិ ។

## មាត្រា៤
## នីតិវិធីក្នុងការដាក់សំណុំលិខិតស្នើសុំអន្តរជាតិ

១- [ ការដាក់ដោយផ្ទាល់ឬមិនផ្ទាល់ ]

ក- អាស្រ័យលើការជ្រើសរើសរបស់អ្នកដាក់ពាក្យសុំ សំណុំលិខិតស្នើសុំអាចត្រូវបានដាក់ដោយផ្ទាល់នៅការិយាល័យអន្តរជាតិ ឬក៏ដាក់តាមរយៈការិយាល័យនៃភាគីហត្ថលេខីរបស់អ្នកដាក់ពាក្យសុំ ។

ខ-ថ្វីបើមានចែងក្នុងអនុកថាខណ្ឌ(ក)ក៏ដោយ ភាគីហត្ថលេខីណាមួយអាចជូនដំណឹងទៅអគ្គនាយកតាមរយៈសេចក្តីប្រកាស ថាសំណុំលិខិតស្នើសុំអន្តរជាតិអាចមិនបានដាក់តាមរយៈការិយាល័យរបស់ខ្លួន ។

២- [ កម្រៃក្នុងការបញ្ជូនក្នុងករណីដាក់មិនផ្ទាល់ ] ការិយាល័យរបស់ភាគីហត្ថលេខីណាមួយអាចទាមទារឱ្យអ្នកដាក់ពាក្យសុំ បង់កម្រៃបញ្ជូនមកឱ្យខ្លួន ចំពោះសំណុំលិខិតស្នើសុំអន្តរជាតិណាមួយដែលបានដាក់តាមរយៈការិយាល័យ ដើម្បីជាប្រយោជន៍ផ្ទាល់របស់ការិយាល័យ ។

## មាត្រា៥
## ខ្លឹមសារនៃសំណុំលិខិតស្នើសុំអន្តរជាតិ

១- [ ខ្លឹមសារនៃសំណុំលិខិតស្នើសុំអន្តរជាតិដែលច្បាប់តម្រូវ ] សំណុំលិខិតស្នើសុំអន្តរជាតិត្រូវធ្វើជាភាសាដែលបានកំណត់ ឬធ្វើជាភាសាមួយក្នុងចំណោមភាសាដែលបានកំណត់ហើយត្រូវមានឬអមមកជាមួយដោយៈ

(i) ពាក្យសុំចុះបញ្ជីអន្តរជាតិតាមច្បាប់នេះ

(ii) ទិន្នន័យដែលបានកំណត់អំពីអ្នកដាក់ពាក្យសុំ

(iii) ចំនួនកំណត់នៃច្បាប់ចម្លងដែលត្រូវផលិតឡើងវិញ ឬ តាមជម្រើសរបស់អ្នកដាក់ពាក្យសុំ ចំនួនកំណត់នៃការផលិតឡើងវិញផ្សេងទៀតនៃគំនូរឧស្សាហកម្ម ដែលជាកម្មវត្ថុនៃសំណុំលិខិតស្នើសុំអន្តរជាតិ ដែលត្រូវបង្ហាញតាមរបៀបដែលបានកំណត់ ។ ប៉ុន្តែ នៅពេលដែលគំនូរឧស្សាហកម្មជាគំនូរទម្រង់ពីរវិមាត្រហើយនៅពេលដែលពាក្យសុំពន្យារការចុះផ្សាយត្រូវបានធ្វើឡើងស្របតាមកថាខណ្ឌ(៥) នោះសំណុំលិខិតស្នើសុំអន្តរជាតិអាចអមដោយរូបសំណាកនៃគំនូរឧស្សាហកម្មតាមចំនួនដែលបានកំណត់ ជំនួសឱ្យការផលិតឡើងវិញ ។

(iv) ការចង្អុលបង្ហាញពីផលិតផល ឬផលិតផលទាំងឡាយដែលបង្កើតជាគំនូរឧស្សាហកម្ម ឬមានទំទាក់ទំនងជាមួយការប្រើប្រាស់គំនូរឧស្សាហកម្មតាមការកំណត់

(v) ការចង្អុលបង្ហាញពីភាគីហត្ថលេខីជ្រើសរើស

(vi) កម្រៃកំណត់

(vii) ចំនុចពិសេសផ្សេងៗទៀតដូចដែលបានកំណត់ ។

២- [ ខ្លឹមសារបន្ថែមនៃសំណុំលិខិតស្នើសុំអន្តរជាតិដែលច្បាប់តម្រូវ ]

ក-នៅពេលភាគីហត្ថលេខីក្លាយជាភាគីនៃច្បាប់នេះ ភាគីហត្ថលេខីណាមួយដែលមានការិយាល័យជាការិយាល័យត្រួតពិនិត្យ និងមានច្បាប់របស់ខ្លួនតម្រូវឱ្យសំណុំលិខិតស្នើសុំដើម្បីផ្តល់នូវកិច្ចការពារចំពោះគំនូរឧស្សាហកម្ម មាននូវធាតុណាមួយដូចបានកំណត់នៅក្នុងអនុកថាខណ្ឌ(ខ) ដើម្បីឱ្យសំណុំលិខិតស្នើសុំនោះត្រូវបានចុះកាលបរិច្ឆេទតាមច្បាប់ អាចជូនដំណឹងទៅអគ្គនាយកអំពីធាតុផ្សំទាំងនោះ តាមរយៈសេចក្តីប្រកាស ។

ខ- ធាតុផ្សំទាំងឡាយដែលអាចត្រូវបានជូនដំណឹងតាមអនុកថាខណ្ឌ(ក) មានដូចខាងក្រោម:

(i) ការចង្អុលបង្ហាញអំពីអត្តសញ្ញាណនៃអ្នកបង្កើតគំនូរឧស្សាហកម្មដែលជាកម្មវត្ថុនៃសំណុំលិខិតស្នើសុំ

(ii) សេចក្តីអធិប្បាយសង្ខេបអំពីការផលិតឡើងវិញ ឬអំពីរូបរាងពិសេសរបស់គំនូរឧស្សាហកម្មដែលជាកម្មវត្ថុនៃសំណុំលិខិតស្នើសុំ

(iii) សេចក្តីអះអាង ។

គ- នៅពេលដែលសំណុំលិខិតស្នើសុំអន្តរជាតិមាននូវការជ្រើសរើសភាគីហត្ថលេខីដោយបានធ្វើសេចក្តីជូនដំណឹងតាមអនុកថាខណ្ឌ(ក) សំណុំលិខិតស្នើសុំនោះក៏ត្រូវមាននូវធាតុណាមួយ ដែលជាកម្មវត្ថុនៃការជូនដំណឹងក្នុងរបៀបដែលបានកំណត់ ។

៣- [ ខ្លឹមសារផ្សេងទៀតនៃសំណុំលិខិតស្នើសុំអន្តរជាតិ ] សំណុំលិខិតស្នើសុំអន្តរជាតិអាចមាន ឬអមមកជាមួយដោយធាតុផ្សេងៗទៀតដូចដែលបានបញ្ជាក់នៅក្នុងបទបញ្ជា ។

៤- [ គំនូរឧស្សាហកម្មមួយចំនួននៅក្នុងសំណុំលិខិតស្នើសុំអន្តរជាតិតែមួយ ] យោងតាមលក្ខខណ្ឌដែលអាចត្រូវបានកំណត់ គំនូរឧស្សាហកម្មពីរឬច្រើន អាចធ្វើសំណុំលិខិតស្នើសុំអន្តរជាតិតែមួយបាន ។

៥- [ ពាក្យសុំពន្យារការចុះផ្សាយ ] សំណុំលិខិតស្នើសុំអន្តរជាតិអាចមាន នូវពាក្យសុំពន្យារការចុះផ្សាយ ។

## មាត្រា៦
## អាទិភាព

១- [ ការអះអាងអាទិភាព ]

ក- យោងតាមមាត្រា៤ នៃអនុសញ្ញាទីក្រុងប៉ារីស សំណុំលិខិតស្នើសុំអន្តរជាតិ អាច មានសេចក្តីប្រកាសអះអាងអំពីអាទិភាព នៃសំណុំលិខិតស្នើសុំដំបូងមួយឬច្រើន ដែលបានដាក់ក្នុង ឬក្នុងនាមប្រទេសណាមួយជាភាគីនៃអនុសញ្ញានេះ ឬសមាជិកណា មួយនៃអង្គការពាណិជ្ជកម្មពិភពលោក ។

ខ- បទបញ្ជាអាចចែងថាសេចក្តីប្រកាសដូចមានចែងនៅក្នុងអនុកថាខណ្ឌ(ក)ខាង លើ អាចត្រូវបានធ្វើឡើង បន្ទាប់ពីការដាក់សំណុំលិខិតស្នើសុំអន្តរជាតិ ។ នៅក្នុងករណី នេះ បទបញ្ជាត្រូវកំណត់ពីរយៈពេលចុងក្រោយបំផុត ដែលអាចធ្វើសេចក្តីប្រកាសនេះ ។

២- [ សំណុំលិខិតស្នើសុំអន្តរជាតិដែលជាមូលដ្ឋានក្នុងការអះអាងអំពីអាទិភាព ] ចាប់ពី កាលបរិច្ឆេទសុំចុះបញ្ជីនឹងទោះបីជាមានលទ្ធផលយ៉ាងណាក៏ដោយ សំណុំលិខិតស្នើសុំ អន្តរជាតិត្រូវសមមូលទៅនឹងការដាក់ពាក្យសុំធម្មតា ក្នុងអត្ថន័យនៃមាត្រា៤ នៃអនុសញ្ញា ទីក្រុងប៉ារីស។

## មាត្រា៧
## កម្រៃក្នុងការជ្រើសរើស

១- [ កម្រៃជ្រើសរើសដែលបានកំណត់] លើកលែងកថាខណ្ឌ(២) កម្រៃកំណត់ត្រូវបញ្ចូល នូវកម្រៃជ្រើសរើសចំពោះភាគីហត្ថលេខីជ្រើសរើសនីមួយៗ ។

២-[១] [ កម្រៃក្នុងការជ្រើសរើសដោយឡែក ] ភាគីហត្ថលេខីណាមួយដែលមានការិយា ល័យជាការិយាល័យត្រួតពិនិត្យ និងភាគីហត្ថលេខីណាមួយដែលជាអង្គការអន្តររដ្ឋាភិ

---

[១] [កំណត់របស់WIPO]: អនុសាសន៍ដែលបានអនុម័តដោយសន្និបាតនៃសហភាពឡាអេ:
" ភាគីហត្ថលេខីទាំងឡាយដែលធ្វើ ឬដែលបានធ្វើ សេចក្តីប្រកាសតាមមាត្រា៧(២) នៃច្បាប់ឆ្នាំ១៩៩៩ ឬតាមប្រកា ៣៦(១) នៃបទប្បញ្ញត្តិរួម ត្រូវបានលើកទឹកចិត្តក្នុងសេចក្តីប្រកាសនោះ ឬក្នុងសេចក្តីប្រកាសថ្មីមួយ ចំពោះសំណុំលិខិត ស្នើសុំអន្តរជាតិដែលបានដាក់ដោយអ្នកដាក់ពាក្យសុំដែលមានការផ្តល់សិទ្ធិតែមួយគត់ពាក់ព័ន្ធនឹងប្រទេសដែលមានការ អភិវឌ្ឍន៍តិចតួច ស្របតាមបញ្ជីដែលបានបង្កើតដោយអង្គការសហប្រជាជាតិ ឬស្របតាមអង្គការអន្តររដ្ឋាភិបាលដែល រដ្ឋជាសមាជិកទាំងនោះភាគច្រើនជាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច ឱ្យបង្ហាញថាកម្រៃដោយឡែកដែលអាច បង់បានចំពោះការជ្រើសរើសត្រូវបានកាត់បន្ថយ១០%នៃចំនួនដែលបានកំណត់ (បើចាំបាច់ បន្ថែមឱ្យគ្រប់ទៅនឹងតួលេខ ធំដែលនៅជិតបំផុត) ។ ភាគីហត្ថលេខីទាំងនោះត្រូវបានលើកទឹកចិត្តបន្ថែមទៀតដើម្បីកំណត់ថាការកាត់បន្ថយក៏ត្រូវ

បាលពាក់ព័ន្ធនឹងសំណុំលិខិតស្នើសុំអន្តរជាតិណាមួយ ដែលត្រូវបានជ្រើសរើសឡើង ព្រមទាំងពាក់ព័ន្ធនឹងការចុះបញ្ជីអន្តរជាតិសារឡើងវិញ ដែលកើតចេញពីសំណុំលិខិតស្នើសុំអន្តរជាតិនេះ អាចជូនដំណឹងទៅអគ្គនាយកតាមរយៈសេចក្តីប្រកាស ថាកម្រៃជ្រើសរើស ដែលបានកំណត់ដូចមានចែងក្នុងកថាខណ្ឌ(១) ត្រូវជំនួសដោយកម្រៃជ្រើសរើសដោយឡែកៗ ដែលចំនួននៃកម្រៃនេះត្រូវកំណត់ក្នុងសេចក្តីប្រកាស ហើយអាចត្រូវផ្លាស់ប្តូរដោយសេចក្តីប្រកាសក្រោយៗទៀត ។ ចំនួនខាងលើនេះអាចកំណត់ដោយភាគីហាត្ថលេខីខាងលើសម្រាប់រយៈពេលដំបូងនៃកិច្ចការពារ និង សម្រាប់រយៈពេលនៃការចុះបញ្ជីសារឡើងវិញម្តងៗ ឬ សម្រាប់រយៈពេលអតិបរមានៃកិច្ចការពារដែលភាគីហាត្ថលេខីពាក់ព័ន្ធបានផ្តល់ឱ្យ ។ ប៉ុន្តែចំនួននេះមិនអាចខ្ពស់ជាងចំនួនសមមូលដែលការិយាល័យនៃភាគីហាត្ថលេខី មានសិទ្ធិទទួលបានពីអ្នកដាក់ពាក្យសុំឱ្យការពារ ក្នុងរយៈពេលសមមូលតាមចំនួនតែមួយនៃគំនូរឧស្សាហកម្មឡើយ ។ ចំនួននេះត្រូវបានបន្ថយតាមរយៈការសន្សំដែលកើតចេញពីនីតិវិធីអន្តរជាតិ ។

៣- [ ការបញ្ជូនកម្រៃក្នុងការជ្រើសរើស ] កម្រៃក្នុងការជ្រើសរើសដូចមានចែងនៅក្នុងកថាខណ្ឌ(១) និងកថាខណ្ឌ(២) ត្រូវបញ្ជូនដោយការិយាល័យអន្តរជាតិទៅកាន់ភាគីហាត្ថលេខីចំពោះកម្រៃដែលបានបង់ ។

## មាត្រា៨
## ការកែតម្រូវកំហុស

១- [ ការត្រួតពិនិត្យសំណុំលិខិតស្នើសុំអន្តរជាតិ ] នៅពេលបានទទួលសំណុំលិខិតស្នើសុំអន្តរជាតិ ប្រសិនបើការិយាល័យអន្តរជាតិពិនិត្យឃើញថាសំណុំលិខិតស្នើសុំអន្តរជាតិនេះមិនបានបំពេញត្រឹមត្រូវទៅតាមលក្ខខណ្ឌនៃច្បាប់នេះ និងបទបញ្ជាទេ ការិយាល័យអន្តរជាតិត្រូវអញ្ជើញឱ្យអ្នកដាក់ពាក្យសុំធ្វើការកែតម្រូវក្នុងរយៈពេលណាមួយជាកំណត់ ។

២- [ កំហុសដែលមិនបានកែតម្រូវ ]

ក- លើកលែងអនុកថាខណ្ឌ(ខ) ប្រសិនបើអ្នកដាក់ពាក្យសុំមិនបានអនុវត្តតាមការ

---

បានអនុវត្តផងដែរចំពោះសំណុំលិខិតស្នើសុំអន្តរជាតិដែលបានដាក់ដោយអ្នកដាក់ពាក្យសុំដែលការផ្តល់សិទ្ធិមិនមែនពាក់ព័ន្ធតែមួយទៅនឹងអង្គការអន្តររដ្ឋាភិបាល ឱ្យតែការផ្តល់សិទ្ធិផ្សេងៗទៀតរបស់អ្នកដាក់ពាក្យសុំពាក់ព័ន្ធនឹងភាគីហាត្ថលេខីដែលជាប្រទេសមានការអភិវឌ្ឍន៍តិចតួច ឬប្រសិនបើមិនមែនជាប្រទេសដែលមានការអភិវឌ្ឍន៍តិចតួច គឺជារដ្ឋសមាជិកនៃអង្គការអន្តររដ្ឋាភិបាលនោះ ហើយសំណុំលិខិតស្នើសុំអន្តរជាតិនឹងត្រូវគ្រប់គ្រងផ្តាច់មុខដោយច្បាប់ឆ្នាំ ១៩៩៩ ។

អញ្ជើញក្នុងពេលដែលបានកំណត់ទេ សំណុំលិខិតស្នើសុំអន្តរជាតិត្រូវចាត់ទុកថាបាន បោះបង់ចោល ។

ខ-ក្នុងករណីដែលមានកំហុសពាក់ព័ន្ធនឹងមាត្រា៥(២) ឬ ពាក់ព័ន្ធនឹងលក្ខខណ្ឌពិសេសដែលភាគីហត្ថលេខីមួយបានជូនដំណឹងទៅអគ្គនាយកតាមបទបញ្ជា ប្រសិនបើអ្នកដាក់ពាក្យសុំមិនបានអនុវត្តតាមការអញ្ជើញក្នុងពេលកំណត់ទេ សំណុំលិខិតស្នើសុំអន្តរជាតិត្រូវចាត់ទុកថាមិនបានកំនត់អំពីការជ្រើសរើសភាគីហត្ថលេខីនោះទេ ។

## មាត្រា៩
## កាលបរិច្ឆេទសុំចុះបញ្ជីសំណុំលិខិតស្នើសុំអន្តរជាតិ

១- [ សំណុំលិខិតស្នើសុំអន្តរជាតិដែលបានដាក់ដោយផ្ទាល់ ] លើកលែងកថាខណ្ឌ(៣) នៅពេលដែលសំណុំលិខិតស្នើសុំអន្តរជាតិ បានដាក់ដោយផ្ទាល់ នៅការិយាល័យអន្តរជាតិ កាលបរិច្ឆេទសុំចុះបញ្ជី ត្រូវតែជាកាលបរិច្ឆេទដែលការិយាល័យអន្តរជាតិទទួលបាននូវសំណុំលិខិតស្នើសុំអន្តរជាតិនេះ ។

២- [ សំណុំលិខិតស្នើសុំអន្តរជាតិដែលបានដាក់មិនផ្ទាល់ ] នៅពេលដែលសំណុំលិខិតស្នើសុំអន្តរជាតិបានដាក់តាមរយៈការិយាល័យ នៃភាគីហត្ថលេខីរបស់អ្នកដាក់ពាក្យសុំ កាលបរិច្ឆេទសុំចុះបញ្ជី ត្រូវបានកំណត់តាមកាលបរិច្ឆេទដែលបានចែង ។

៣- [ សំណុំលិខិតស្នើសុំអន្តរជាតិដែលមានកំហុសមួយចំនួន ] តាមកាលបរិច្ឆេទដែលការិយាល័យអន្តរជាតិបានទទួលសំណុំលិខិតស្នើសុំអន្តរជាតិ នៅពេលសំណុំលិខិតស្នើសុំអន្តរជាតិមានកំហុស ដែលអាចកំណត់បានថាជាកំហុសដែលបណ្តាលឱ្យមានការពន្យារពេលកាលបរិច្ឆេទសុំចុះបញ្ជីសំណុំលិខិតស្នើសុំអន្តរជាតិ កាលបរិច្ឆេទសុំចុះបញ្ជីត្រូវតែជាកាលបរិច្ឆេទនៃការកែតម្រូវកំហុសដែលការិយាល័យអន្តរជាតិបានទទួល ។

## មាត្រា១០[២]

## ការចុះបញ្ជីអន្តរជាតិ កាលបរិច្ឆេទចុះបញ្ជីអន្តរជាតិ ការចុះផ្សាយ និងច្បាប់ចម្លងសំងាត់នៃការចុះបញ្ជីអន្តរជាតិ

១- [ ការចុះបញ្ជីអន្តរជាតិ ] ការិយាល័យអន្តរជាតិត្រូវចុះបញ្ជីគំនូរឧស្សាហកម្មនីមួយៗ ដែលជាកម្មវត្ថុនៃសំណុំលិខិតស្នើសុំអន្តរជាតិភ្លាម នៅពេលដែលការិយាល័យអន្តរជាតិបានទទួលនូវសំណុំលិខិតស្នើសុំអន្តរជាតិ ឬនៅពេលមានការស្នើសុំឱ្យកែតម្រូវតាមមាត្រា៨ ត្រូវចុះបញ្ជីភ្លាមបន្ទាប់ពីបានទទួលការកែតម្រូវដែលបានស្នើសុំ។ ត្រូវទទួលចុះបញ្ជី ទោះបីជាមាន ឬគ្មានការពន្យារការចុះផ្សាយតាមមាត្រា១១ ក៏ដោយ ។

២- [ កាលបរិច្ឆេទចុះបញ្ជីអន្តរជាតិ ]

ក- លើកលែងអនុកថាខណ្ឌ(ខ) កាលបរិច្ឆេទចុះបញ្ជីអន្តរជាតិ ជាកាលបរិច្ឆេទសុំចុះបញ្ជីសំណុំលិខិតស្នើសុំអន្តរជាតិ ។

ខ- តាមកាលបរិច្ឆេទដែលការិយាល័យអន្តរជាតិទទួលបានសំណុំលិខិតស្នើសុំអន្តរជាតិ នៅពេលដែលសំណុំលិខិតស្នើសុំអន្តរជាតិមានកំហុសពាក់ព័ន្ធនឹងមាត្រា៥(២) កាលបរិច្ឆេទចុះបញ្ជីអន្តរជាតិ ជាកាលបរិច្ឆេទដែលការិយាល័យអន្តរជាតិទទួលបានការកែតម្រូវកំហុស ឬកាលបរិច្ឆេទសុំចុះបញ្ជីសំណុំលិខិតស្នើសុំអន្តរ ដោយយកកាលបរិច្ឆេទមួយណាដែលក្រោយគេ ។

៣- [ ការចុះផ្សាយ ]

ក- ការិយាល័យអន្តរជាតិត្រូវចុះផ្សាយការចុះបញ្ជី។ ក្នុងដែនដីនៃភាគីហត្ថលេខីទាំងអស់ ការចុះផ្សាយនេះត្រូវចាត់ទុកថាមានលក្ខណៈជាសាធារណៈគ្រប់គ្រាន់ ហើយមិនតម្រូវឱ្យមានការផ្សាយជាសាធារណៈផ្សេងទៀតពីម្ចាស់សិទ្ធិឡើយ ។

ខ- ការិយាល័យអន្តរជាតិ ត្រូវផ្ញើច្បាប់ចម្លងអំពីការចុះផ្សាយការចុះបញ្ជីអន្តរជាតិទៅកាន់ការិយាល័យជ្រើសរើសនីមួយៗ ។

---

[២] នៅពេលអនុម័តមាត្រា១០ សន្និសីទការទូតបានយល់ថា មាត្រានេះមិនអាចរារាំងដល់ការទទួលបានសំណុំលិខិតស្នើសុំអន្តរជាតិ ឬការចុះបញ្ជីអន្តរជាតិដោយអ្នកដាក់ពាក្យសុំ ឬម្ចាស់សិទ្ធិ ឬបុគ្គលណាម្នាក់ដែលមាន ការអនុញ្ញាតពីអ្នកដាក់ពាក្យសុំឬម្ចាស់សិទ្ធិ។

៤- [ ការរក្សាការសំងាត់មុនការចុះផ្សាយ ] លើកលែងកថាខណ្ឌ (៥) និងមាត្រា១១(៤)(ខ) ការិយាល័យអន្តរជាតិត្រូវរក្សាការសំងាត់នៃសំណុំលិខិតស្នើសុំអន្តរជាតិ និងការចុះបញ្ជីអន្តរជាតិនីមួយៗ រហូតដល់មានការចុះផ្សាយ ។

៥- [ ច្បាប់ចម្លងសំងាត់ ]

ក-បន្ទាប់ពីបានចុះបញ្ជីភ្លាម ការិយាល័យអន្តរជាតិត្រូវផ្ញើច្បាប់ចម្លងនៃការចុះបញ្ជីអន្តរជាតិ ជាមួយនឹងសេចក្តីអះអាងដែលពាក់ព័ន្ធ ឯកសារ ឬរបសំណាកដែលភ្ជាប់ក្នុងសំណុំលិខិតស្នើសុំអន្តរជាតិទៅកាន់ការិយាល័យនីមួយៗ ដែលបានជូនដំណឹងមកកាន់ការិយាល័យអន្តរជាតិ ថាការិយាល័យខ្លួនចង់បាន ច្បាប់ចម្លងនេះហើយការិយាល័យនេះត្រូវបានជ្រើសរើសក្នុងសំណុំលិខិតស្នើសុំអន្តរជាតិ ។

ខ- រហូតដល់មានការចុះផ្សាយការចុះបញ្ជីអន្តរជាតិដោយការិយាល័យអន្តរជាតិ ការិយាល័យត្រូវរក្សាជាសំងាត់នូវការចុះបញ្ជីអន្តរជាតិនីមួយៗ ដែលមានច្បាប់ចម្លងត្រូវបានការិយាល័យអន្តរជាតិផ្ញើមកឱ្យខ្លួន ហើយការិយាល័យអាចប្រើប្រាស់ច្បាប់ចម្លងនេះសម្រាប់តែគោលបំណងនៃការត្រួតពិនិត្យការចុះបញ្ជីអន្តរជាតិ និងសម្រាប់តែគោលបំណងនៃការដាក់ពាក្យសុំការពារគំនូរឧស្សាហកម្មដែលបានដាក់ក្នុងឬក្នុងនាមភាគីហត្ថលេខីដែលការិយាល័យមានសមត្ថកិច្ច ។ ជាពិសេសការិយាល័យ មិនត្រូវផ្សព្វផ្សាយខ្លឹមសារនៃការចុះបញ្ជីអន្តរជាតិទៅឱ្យបុគ្គលណាម្នាក់នៅក្រៅការិយាល័យ ក្រៅពីម្ចាស់សិទ្ធិនៃការចុះបញ្ជីអន្តរជាតិនោះទេ លើកលែងតែក្នុងគោលបំណងនៃនីតិវិធីរដ្ឋបាល ឬច្បាប់ដែលពាក់ព័ន្ធនឹងវិវាទលើសិទ្ធិក្នុងការដាក់សំណុំលិខិតស្នើសុំអន្តរជាតិ ដែលជាមូលដ្ឋាននៃការចុះបញ្ជីអន្តរជាតិ ។ ចំពោះនីតិវិធីរដ្ឋបាល ឬ ច្បាប់នេះ ខ្លឹមសារនៃការចុះបញ្ជីអន្តរជាតិអាចត្រូវបង្ហាញជាសម្ងាត់តែចំពោះ ភាគីទាំងឡាយដែលពាក់ព័ន្ធក្នុងនីតិវិធីនេះដែលមានកាតព្វកិច្ចគោរពការសំងាត់ទាក់ទងនឹងការបង្ហាញ ។

## មាត្រា១១
## ការពន្យារការចុះផ្សាយ

១-[ បទប្បញ្ញត្តិនៃច្បាប់របស់ភាគីហត្ថលេខីស្តីពីការពន្យារការចុះផ្សាយ ]

ក- នៅពេលច្បាប់របស់ភាគីហត្ថលេខីចែងអំពីការពន្យារការចុះផ្សាយគំនូរឧស្សាហកម្មក្នុងរយៈពេលដែលតិចជាងរយៈពេលកំណត់ ភាគីហត្ថលេខីនោះត្រូវជូនដំណឹងទៅអគ្គនាយកតាមរយៈសេចក្តីប្រកាសមួយ អំពីរយៈពេលដែលអាចអនុញ្ញាតបាននៃការពន្យារនេះ ។

ខ- នៅពេលច្បាប់របស់ភាគីហត្ថលេខីមិនបានចែងអំពីការពន្យារការចុះផ្សាយគំនូរឧស្សាហកម្មទេ ភាគីហត្ថលេខីត្រូវជូនដំណឹងអគ្គនាយកអំពីបញ្ហានេះតាមរយៈសេចក្តីប្រកាស ។

២- [ ការពន្យារការចុះផ្សាយ ] នៅពេលសំណុំលិខិតស្នើសុំអន្តរជាតិមានពាក្យសុំពន្យារការចុះផ្សាយ ត្រូវធ្វើការចុះផ្សាយ

(i) នៅពេលផុតរយៈពេលកំណត់ ប្រសិនបើគ្មានភាគីហត្ថលេខីត្រូវបានជ្រើសរើសនៅក្នុងសំណុំលិខិតស្នើសុំអន្តរជាតិបានប្រកាសតាមកថាខណ្ឌ (១) ឬ

(ii) នៅពេលភាគីហត្ថលេខីណាមួយត្រូវបានជ្រើសរើសនៅក្នុងសំណុំលិខិតស្នើសុំអន្តរជាតិដែលបានប្រកាសតាមកថាខណ្ឌ(១)(ក) នៅពេលផុតរយៈពេលដែលបានជូនដំណឹងក្នុងសេចក្តីប្រកាសនេះ ឬនៅពេលមានភាគីហត្ថលេខីជ្រើសរើសច្រើនជាងមួយនៅពេលផុតរយៈពេលខ្លីបំផុតដូចបានជូនដំណឹងក្នុងសេចក្តីប្រកាស ។

៣- [ ប្រព្រឹត្តកម្មនៃពាក្យសុំពន្យារនៅពេលការពន្យារមិនអាចធ្វើបានតាមច្បាប់ដែលត្រូវអនុវត្ត ] នៅពេលមានការស្នើសុំការពន្យាការចុះផ្សាយហើយភាគីហត្ថលេខីណាមួយដែលត្រូវបានជ្រើសរើសនៅក្នុងសំណុំលិខិតស្នើសុំអន្តរជាតិបាន ប្រកាសតាមកថាខណ្ឌ(១)(ខ) ការពន្យារការចុះផ្សាយមិនអាចធ្វើឡើងតាមច្បាប់របស់ខ្លួនបានឡើយ ។

(i) លើកលែងចំនុច(ii) ការិយាល័យអន្តរជាតិត្រូវជូនដំណឹងទៅអ្នកដាក់ពាក្យសុំ។ ការិយាល័យអន្តរជាតិត្រូវបដិសេធពាក្យសុំពន្យារការចុះផ្សាយ ប្រសិនបើក្នុងរយៈពេលដែលបានកំណត់ អ្នកដាក់ពាក្យសុំមិនបានដកការជ្រើសរើសភាគីហត្ថលេខីខាងលើតាមរយៈលិខិតជាលាយលក្ខណ៍អក្សរទៅកាន់ការិយាល័យអន្តរជាតិ ។

(ii) ជំនួសឱ្យការភ្ជាប់ការផលិតឡើងវិញនៃគំនូរឧស្សាហកម្ម នៅពេលដែលសំណុំលិខិតស្នើសុំអន្តរជាតិត្រូវបានភ្ជាប់មកជាមួយដោយរូបសំណាកគំនូរឧស្សាហកម្ម ការិយាល័យអន្តរជាតិ ត្រូវបដិសេធការជ្រើសរើសភាគីហត្ថលេខីនេះនិងត្រូវជូនដំណឹងទៅអ្នកដាក់ពាក្យសុំអំពីរឿងនេះ។

៤- [សំណើសុំឱ្យមានការចុះផ្សាយមុនឬ សំណើសុំឱ្យទទួលបានសិទ្ធិពិសេសចំពោះការចុះបញ្ជីអន្តរជាតិ ]

ក- ពេលណាក៏បានក្នុងរយៈពេលនៃការពន្យារតាមកថាខណ្ឌ(២) ម្ចាស់សិទ្ធិអាចស្នើសុំចុះផ្សាយនូវគំនូរឧស្សាហកម្មណាមួយឬទាំងអស់ ដែលជាកម្មវត្ថុនៃការចុះបញ្ជីអន្តរជាតិ ។ នៅក្នុងករណីនេះ រយៈពេលពន្យារគំនូរឧស្សាហកម្មមួយ ឬច្រើនត្រូវបាន

ចាត់ទុកថាផុតរយៈពេលតាមកាលបរិច្ឆេទដែល ការិយាល័យអន្តរជាតិទទួលបានសំណើនេះ ។

ខ- ពេលណាក៏បានក្នុងរយៈពេលនៃការពន្យារតាមកថាខណ្ឌ(២) ម្ចាស់សិទ្ធិក៏អាចស្នើសុំ ទៅការិយាល័យអន្តរជាតិដើម្បីផ្តល់ឱ្យភាគីទី៣ ដែលបានបញ្ជាក់ដោយម្ចាស់សិទ្ធិនូវសម្រង់នៃគំនូរឧស្សាហកម្មណាមួយឬទាំងអស់ដែលជាកម្មវត្ថុនៃការចុះបញ្ជីអន្តរជាតិ ឬអនុញ្ញាតឱ្យភាគីនេះមានសិទ្ធិលើគំនូរឧស្សាហកម្មនេះ ។

៥- [ការបោះបង់ និងការកម្រិត ]

ក- ពេលណាក៏បានក្នុងរយៈពេលនៃការពន្យារតាមកថាខណ្ឌ(២) ប្រសិនបើម្ចាស់សិទ្ធិបានបោះបង់ការចុះបញ្ជីអន្តរជាតិចំពោះភាគីហត្ថលេខីជ្រើសរើសទាំងអស់ នោះគំនូរឧស្សាហកម្មមួយឬច្រើនដែលជាកម្មវត្ថុនៃការចុះបញ្ជីអន្តរជាតិមិនត្រូវបានចុះផ្សាយឡើយ ។

ខ- ពេលណាក៏បានក្នុងរយៈពេលនៃការពន្យារតាមកថាខណ្ឌ(២) ប្រសិនបើម្ចាស់សិទ្ធិកម្រិតនូវគំនូរឧស្សាហកម្ម មួយឬច្រើនដែលជាកម្មវត្ថុនៃការចុះបញ្ជីអន្តរជាតិ គំនូរឧស្សាហកម្មមួយឬច្រើនផ្សេងទៀត ដែលជាកម្មវត្ថុនៃការចុះបញ្ជីអន្តរជាតិមិនត្រូវបានចុះផ្សាយឡើយ ។

៦- [ ការចុះផ្សាយ និងការផ្តល់ការផលិតឡើងវិញ ]

ក- ពេលផុតកំណត់រយៈពេលពន្យារ តាមបទប្បញ្ញត្តិនៃមាត្រានេះ ការិយាល័យអន្តរជាតិត្រូវចុះផ្សាយការចុះបញ្ជីអន្តរជាតិដែលជាកម្មវត្ថុនៃការបង់កម្រៃកំណត់។ ប្រសិនបើកម្រៃមិនទាន់បានបង់តាមការកំណត់ទេ ការចុះបញ្ជីអន្តរជាតិនឹងត្រូវលុបចោល ហើយមិនត្រូវធ្វើការចុះផ្សាយឡើយ ។

ខ- នៅពេលសំណុំលិខិតស្នើសុំអន្តរជាតិត្រូវបានភ្ជាប់ដោយរូបសំណាកគំនូរឧស្សាហកម្មមួយឬច្រើន ស្របតាមមាត្រា៥(១)(iii) ម្ចាស់សិទ្ធិត្រូវភ្ជាប់នូវចំនួនកំណត់នៃច្បាប់ចម្លងនៃការផលិតឡើងវិញនៃគំនូរឧស្សាហកម្មនីមួយដែលជាកម្មវត្ថុនៃសំណុំលិខិតស្នើសុំទៅកាន់ការិយាល័យអន្តរជាតិក្នុងរយៈពេលណាមួយជាកំណត់ ។ ក្នុងករណីដែលម្ចាស់សិទ្ធិមិនបានធ្វើដូច្នេះទេ ការចុះបញ្ជីអន្តរជាតិនឹងត្រូវបដិសេធហើយមិនត្រូវធ្វើការចុះផ្សាយឡើយ ។

## មាត្រា១២
## ការបដិសេធ

១- [ សិទ្ធិបដិសេធ ] នៅពេលដែលលក្ខខណ្ឌដើម្បីផ្តល់នូវកិច្ចការពារតាមច្បាប់នៃភាគីហត្ថលេខីមិនបានបំពេញចំពោះគំនូរឧស្សាហកម្មណាមួយ ឬទាំងអស់ដែលជាកម្មវត្ថុនៃការចុះបញ្ជីអន្តរជាតិ ការិយាល័យនៃភាគីហត្ថលេខីជ្រើសរើសណាមួយ អាចបដិសេធអានុភាពលើផ្នែកណាមួយ ឬទាំងអស់នៃការចុះបញ្ជីអន្តរជាតិ នៅក្នុងដែនដីរបស់ភាគីហត្ថលេខីនេះ លុះត្រាតែគ្មានការិយាល័យណាមួយ អាចបដិសេធអានុភាពលើផ្នែកណាមួយ ឬទាំងអស់នៃការចុះបញ្ជីអន្តរជាតិ ដោយមូលហេតុថាលក្ខខណ្ឌទាក់ទងនឹងទម្រង់ ឬខ្លឹមសារនៃសំណុំលិខិតស្នើសុំអន្តរជាតិ ដែលបានចែងក្នុងច្បាប់នេះឬក្នុងបទបញ្ជា ឬជាការបន្ថែមលើច្បាប់ឬបទបញ្ជានេះ ឬផ្សេងពីច្បាប់ឬបទបញ្ជានេះ មិនបានបំពេញតាមច្បាប់នៃភាគីហត្ថលេខីដែលពាក់ព័ន្ធ។

២- [ ការជូនដំណឹងអំពីការបដិសេធ ]

ក- ការិយាល័យត្រូវជូនដំណឹងតាមសេចក្តីជូនដំណឹងទៅកាន់ការិយាល័យអន្តរជាតិ អំពីការបដិសេធអានុភាពនៃការចុះបញ្ជីអន្តរជាតិ ក្នុងរយៈពេលដែលបានកំណត់ ។

ខ- សេចក្តីជូនដំណឹងនៃការបដិសេធណាមួយ ត្រូវបញ្ជាក់ពីមូលហេតុនៃការបដិសេធនេះ ។

៣- [ ការបញ្ជូនសេចក្តីជូនដំណឹងអំពីការបដិសេធ វិធានការដោះស្រាយ ]

ក- ការិយាល័យអន្តរជាតិត្រូវបញ្ជូនជាបន្ទាន់នូវច្បាប់ចម្លងនៃ សេចក្តីជូនដំណឹងអំពីការបដិសេធទៅកាន់ម្ចាស់សិទ្ធិ ។

ខ- ម្ចាស់សិទ្ធិត្រូវទទួលវិធានការដោះស្រាយដូចគ្នា ប្រសិនបើគំនូរឧស្សាហកម្មណាមួយដែលជាកម្មវត្ថុនៃការចុះបញ្ជីអន្តរជាតិ ក៏ជាកម្មវត្ថុនៃសំណុំលិខិតស្នើសុំដើម្បីផ្តល់កិច្ចការពារនៅក្រោមច្បាប់ដែលអាចអនុវត្តបាន ចំពោះការិយាល័យដែលបានបញ្ជូននូវការបដិសេធនោះ ។ វិធានការដោះស្រាយនេះយ៉ាងហោចណាស់ ត្រូវភ្ជាប់នូវលទ្ធភាពនៃការត្រួតពិនិត្យឡើងវិញ ឬការពិនិត្យឡើងវិញនៃការបដិសេធ ឬការប្តឹងតវ៉ាប្រឆាំងនឹងការបដិសេធ ។

៤-[៣] [ ការដកការបដិសេធ ] ការបដិសេធណាមួយអាចត្រូវបានដកទៅវិញនូវផ្នែកណាមួយ ឬ ទាំងអស់នៅពេលណាមួយក៏បានដោយការិយាល័យដែលបានបញ្ជូនការបដិសេធនោះ ។

## មាត្រា១៣
## លក្ខខណ្ឌពិសេសស្តីអំពីការរួមបញ្ចូលតែមួយនៃគំនូរ

១- [ ការជូនដំណឹងអំពីលក្ខខណ្ឌពិសេស ] នៅពេលដែលភាគីហត្ថលេខីក្លាយជាភាគីនៃច្បាប់នេះ ភាគីហត្ថលេខីណាមួយដែលច្បាប់របស់ខ្លួនទាមទារឱ្យគំនូរដែលជាកម្មវត្ថុនៃសំណុំលិខិតស្នើសុំតែមួយគោរពតាមលក្ខខណ្ឌនៃការរួមបញ្ចូលតែមួយនៃគំនូរ ការរួមបញ្ចូលតែមួយនៃផលិតផល ឬការរួមបញ្ចូលតែមួយនៃការប្រើប្រាស់ ឬស្ថិតនៅក្នុងឈុតតែមួយ ឬជាការផ្គុំនៃវត្ថុ ឬទាមទារឱ្យមានតែគំនូរដែលឯករាជ្យនិងដែលអាចញែកបានអាចត្រូវបានទាមទារឱ្យដាក់បញ្ចូលក្នុងសំណុំលិខិតស្នើសុំតែមួយ អាចជូនដំណឹងទៅអគ្គនាយកអំពីរឿងនេះក្នុងសេចក្តីប្រកាសមួយ ។ ប៉ុន្តែ សេចក្តីប្រកាសនេះមិនត្រូវប៉ះពាល់ដល់សិទ្ធិរបស់អ្នកដាក់ពាក្យសុំក្នុងការបញ្ចូលនូវគំនូរឧស្សាហកម្មពីរ ឬច្រើនក្នុងសំណុំលិខិតស្នើសុំអន្តរជាតិតែមួយស្របតាមមាត្រា៥(៤)បានទេ ទោះបីបើសំណុំលិខិតស្នើសុំ បានជ្រើសរើសភាគីហត្ថលេខីដែលបានធ្វើសេចក្តីប្រកាសក៏ដោយ ។

២- [ អានុភាពនៃសេចក្តីប្រកាស ] សេចក្តីប្រកាសនេះត្រូវអនុញ្ញាតឱ្យការិយាល័យនៃភាគីហត្ថលេខីដែលបានធ្វើសេចក្តីប្រកាសនេះ បដិសេធអានុភាពនៃការចុះបញ្ជីអន្តរជាតិដូចមានចែងក្នុងមាត្រា១២(១) រហូតដល់បានគោរពតាមលក្ខខណ្ឌដែលភាគីហត្ថលេខីនេះបានជូនដំណឹង ។

---

[៣] នៅពេលអនុម័តមាត្រា១២(៤) មាត្រា១៨(២)(ខ) និងប្រកា១៨(៤) សន្និសីទការទូតបានយល់ថា ការដកការបដិសេធដោយការិយាល័យដែលបានជូនសេចក្តីជូនដំណឹងអំពីការបដិសេធអាចយកទម្រង់តាមសេចក្តីអះអាង ដែលការិយាល័យពាក់ព័ន្ធបានសម្រេចទទួលយកអានុភាពនៃការចុះបញ្ជីអន្តរជាតិ ចំពោះគំនូរឧស្សាហកម្មទាំងឡាយ ឬគំនូរឧស្សាហកម្មមួយចំនួនដែលពាក់ព័ន្ធនឹងសេចក្តីជូនដំណឹងនៃការបដិសេធ ។ ក៏ត្រូវយល់ផងដែរថាក្នុង រយៈពេលដែលបានអនុញ្ញាតបញ្ជូនសេចក្តីជូនដំណឹងនៃការបដិសេធ ការិយាល័យមួយអាចធ្វើសេចក្តីអះអាងដែលខ្លួនបានសម្រេចទទួលយកអានុភាពនៃការចុះបញ្ជីអន្តរជាតិ ទោះបីបើការិយាល័យនេះមិនបានបញ្ជូនសេចក្តីជូនដំណឹងនៃការបដិសេធក៏ដោយ ។

៣- [ ការបង់កម្រៃបន្ថែមចំពោះការបំបែកការចុះបញ្ជី ] បន្ទាប់ពីមានសេចក្តីជូនដំណឹងអំពីការបដិសេធស្របតាមកថាខណ្ឌ(២) នៅពេលដែលការចុះបញ្ជីអន្តរជាតិត្រូវបានបំបែកនៅឯការិយាល័យពាក់ព័ន្ធ ដើម្បីតទល់នឹងមូលហេតុនៃការបដិសេធ ដូចបានកំណត់ក្នុងសេចក្តីជូនដំណឹង ការិយាល័យត្រូវមានសិទ្ធិយកកម្រៃចំពោះសំណុំលិខិតស្នើសុំអន្តរជាតិបន្ថែមនីមួយៗ ដែលជាការចាំបាច់ដើម្បីជៀសវាងមូលហេតុនៃការបដិសេធនេះ។

## មាត្រា ១៤
## អានុភាពនៃការចុះបញ្ជីអន្តរជាតិ

១- [ អានុភាពដូចគ្នាទៅនឹងការដាក់សំណុំលិខិតស្នើសុំតាមច្បាប់ដែលអាចអនុវត្តបាន ] ចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីអន្តរជាតិ ការចុះបញ្ជីអន្តរជាតិត្រូវមានយ៉ាងហោចណាស់នូវអានុភាពដូចគ្នានៅក្នុងភាគីហត្ថលេខីជ្រើសរើសនីមួយៗ ទៅនឹងការដាក់សំណុំលិខិតស្នើសុំឱ្យការពារជាផម្មតានៃគំនូរឧស្សាហកម្មតាមច្បាប់នៃភាគីហត្ថលេខីនេះ ។
២- [ អានុភាពដូចគ្នាទៅនឹងការផ្តល់កិច្ចការពារតាមច្បាប់ដែលអាចអនុវត្តបាន ]

ក-ការិយាល័យនៃភាគីហត្ថលេខីជ្រើសរើសនីមួយៗ ដែលមិនបានជូនដំណឹងអំពីការបដិសេធស្របតាមមាត្រា១២ ការចុះបញ្ជីអន្តរជាតិត្រូវមានអានុភាពដូចគ្នាទៅនឹងការផ្តល់កិច្ចការពារគំនូរឧស្សាហកម្មតាមច្បាប់របស់ភាគីហត្ថលេខីនេះ ដោយពុំឱ្យហួសពីកាលបរិច្ឆេទនៃការផុតកំណត់រយៈពេលដែលបានអនុញ្ញាត ឱ្យការិយាល័យដើម្បីជូនដំណឹងអំពីការបដិសេធ ឬដោយពុំឱ្យហួសពីរយៈពេលដែលបានកំណត់ នៅក្នុងសេចក្តីប្រកាសនៅពេលភាគីហត្ថលេខីបានធ្វើសេចក្តីប្រកាសដែលពាក់ព័ន្ធតាមបទញ្ញា។

ខ[៤]- នៅពេលដែលការិយាល័យនៃភាគីហត្ថលេខីជ្រើសរើស បានជូនដំណឹងអំពីការបដិសេធហើយក្រោយមកក៏បានដកនូវការបដិសេធលើផ្នែកណាមួយ ឬទាំងអស់នោះមកវិញ នៅពេលដែលមានការដកការបដិសេធចេញការចុះបញ្ជីអន្តរជាតិត្រូវមានអានុភាពដូចគ្នា ទៅនឹងការផ្តល់កិច្ចការពារគំនូរឧស្សាហកម្មតាមច្បាប់នៃភាគីហត្ថលេខីនេះ ដោយពុំឱ្យហួសពីកាលបរិច្ឆេទនៃការដកការបដិសេធ ។

គ- អានុភាពដែលបានផ្តល់ឱ្យចំពោះការចុះបញ្ជីអន្តរជាតិ តាមកថាខណ្ឌនេះត្រូវអនុវត្តចំពោះគំនូរឧស្សាហកម្មមួយឬច្រើន ដែលជាកម្មវត្ថុនៃការចុះបញ្ជីដូចបានទទួលពី

[៤] មើលកំណត់ជើងទំព័រពាក់ព័ន្ធនឹងមាត្រា១២(៤) ។

ការិយាល័យអន្តរជាតិតាមរយៈការិយាល័យជ្រើសរើស ឬប្រសិនបើមាន ដូចដែលបាន វិសោធនកម្មនៅក្នុងនីតិវិធីចំពោះមុខការិយាល័យនោះ ។

៣- [ សេចក្តីប្រកាសស្តីពីអានុភាពនៃការជ្រើសរើសភាគីហត្ថលេខីរបស់អ្នកដាក់ពាក្យសុំ ]

ក- ភាគីហត្ថលេខីណាមួយដែលមានការិយាល័យជាការិយាល័យត្រួតពិនិត្យ អាចជូនដំណឹងទៅអគ្គនាយកតាមរយៈសេចក្តីប្រកាស ថាការជ្រើសរើសភាគីហត្ថលេខីនៅក្នុងការចុះបញ្ជីអន្តរជាតិគ្មានអានុភាពឡើយ នៅពេលភាគីហត្ថលេខីគឺជាភាគីហត្ថលេខីរបស់អ្នកដាក់ពាក្យសុំ ។

ខ- នៅពេលភាគីហត្ថលេខីដែលបានធ្វើសេចក្តីប្រកាសដូចមានចែងនៅក្នុងអនុកថាខណ្ឌ(ក) ត្រូវបង្ហាញក្នុងសំណុំលិខិតស្នើសុំអន្តរជាតិក្នុងនាមជាភាគីហត្ថលេខីរបស់អ្នកដាក់ពាក្យសុំផងនិងក្នុងនាមជាភាគីហត្ថលេខីជ្រើសរើសផង ការិយាល័យអន្តរជាតិត្រូវបដិសេធការជ្រើសរើសភាគីហត្ថលេខី។

## មាត្រា ១៥
## មោឃភាព

១- [ លក្ខខណ្ឌនៃឱកាសការពារ ] ការប្រកាសមោឃភាព អំពីអានុភាពលើផ្នែកណាមួយ ឬទាំងអស់នៃការចុះបញ្ជីអន្តរជាតិនៅក្នុងដែនដីរបស់ភាគីហត្ថលេខី ដោយអាជ្ញាធរមានសមត្ថកិច្ចនៃភាគីហត្ថលេខីជ្រើសរើស មិនអាចប្រកាសដោយគ្មានការទុកឱកាសសមរម្យឱ្យម្ចាស់សិទ្ធិមានលទ្ធភាពក្នុងការការពារសិទ្ធិរបស់ខ្លួននោះទេ ។

២- [ សេចក្តីជូនដំណឹងអំពីមោឃភាព ] ការិយាល័យនៅក្នុងដែនដីរបស់ភាគីហត្ថលេខីដែលអានុភាពនៃការចុះបញ្ជីអន្តរជាតិត្រូវបានធ្វើមោឃភាព ត្រូវជូនដំណឹងទៅកាន់ការិយាល័យអន្តរជាតិ ប្រសិនបើការិយាល័យបានដឹងអំពីមោឃភាពនេះ។

## មាត្រា ១៦
## ការកត់ត្រាការផ្លាស់ប្តូរ និងបញ្ហាផ្សេងទៀតស្តីអំពីការចុះបញ្ជីអន្តរជាតិ

១- [ ការកត់ត្រាការផ្លាស់ប្តូរ និងបញ្ហាផ្សេងទៀត ] ការិយាល័យអន្តរជាតិត្រូវកត់ត្រាក្នុងបញ្ជីអន្តរជាតិដូចបានកំណត់ នូវៈ

(i) ការផ្លាស់ប្តូរម្ចាស់កម្មសិទ្ធិនៃការចុះបញ្ជីអន្តរជាតិចំពោះភាគីហត្ថលេខីជ្រើសរើសណាមួយ ឬទាំងអស់ និងចំពោះគំនូរឧស្សាហកម្មណាមួយឬទាំងអស់ ដែលជា

កម្មវត្ថុនៃការចុះបញ្ជីអន្តរជាតិ លុះត្រាតែម្ចាស់កម្មសិទ្ធិថ្មីមានសិទ្ធិដាក់សំណុំលិខិតស្នើសុំអន្តរជាតិតាមមាត្រា៣

(ii) ការផ្លាស់ប្តូរឈ្មោះ ឬអសយដ្ឋានរបស់ម្ចាស់កម្មសិទ្ធិ

(iii) ការតែងតាំងតំណាងនៃអ្នកដាក់ពាក្យសុំ ឬម្ចាស់សិទ្ធិ និងអង្គហេតុផ្សេងទៀតដែលពាក់ព័ន្ធនឹងអ្នកតំណាងនេះ

(iv) ការបោះបង់សិទ្ធិនៃការចុះបញ្ជីអន្តរជាតិដោយម្ចាស់សិទ្ធិទាក់ទងនឹងភាគីហត្ថលេខីជ្រើសរើសណាមួយឬទាំងអស់

(v) ការកម្រិតណាមួយនៃការចុះបញ្ជីអន្តរជាតិដោយម្ចាស់សិទ្ធិទៅជាគំនូរឧស្សាហកម្មមួយឬច្រើនដែលជាកម្មវត្ថុនៃការចុះបញ្ជីអន្តរជាតិ ទាក់ទងនឹងភាគីហត្ថលេខីជ្រើសរើសណាមួយឬទាំងអស់

(vi) ការប្រកាសមោឃភាពអំពីអានុភាពនៃការចុះបញ្ជីអន្តរជាតិ នៅក្នុងដែនដីនៃភាគីហត្ថលេខី ចំពោះគំនូរឧស្សាហកម្មណាមួយឬទាំងអស់ដែលជាកម្មវត្ថុនៃការចុះបញ្ជីអន្តរជាតិ ដោយអាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីហត្ថលេខីជ្រើសរើស ។

(vii) អង្គហេតុពាក់ព័ន្ធផ្សេងទៀតដូចមាននៅក្នុងបទបញ្ជា ទាក់ទងនឹងសិទ្ធិដែលមានលើគំនូរឧស្សាហកម្មណាមួយឬ ទាំងអស់ដែលជាកម្មវត្ថុនៃការចុះបញ្ជីអន្តរជាតិ ។

២- [ អានុភាពនៃការកត់ត្រាក្នុងបញ្ជីអន្តរជាតិ ] ការកត់ត្រាណាមួយដូចមានចែងក្នុងចំនុច (i), (ii), (iv), (v), (vi) និងចំនុច (vii)នៃកថាខណ្ឌ(១) ត្រូវមានអានុភាពដូច ការកត់ត្រានោះបានធ្វើក្នុងបញ្ជីនៃការិយាល័យរបស់ភាគីហត្ថលេខីពាក់ព័ន្ធនីមួយៗ លើកលែងតែភាគីហត្ថលេខីអាចជូនដំណឹងទៅអគ្គនាយកតាមរយៈសេចក្តីប្រកាស ថាការកត់ត្រាដូចមានចែងក្នុងចំនុច(i)នៃកថាខណ្ឌ(១) មិនមានអានុភាពនៅក្នុងភាគីហត្ថលេខីរហូតដល់ការិយាល័យនៃភាគីហត្ថលេខីបានទទួលនូវសេចក្តីអះអាង ឬឯកសារដូចបានកំណត់ក្នុងសេចក្តីប្រកាសនេះ។

៣- [ កម្រៃ ] ការកត់ត្រាណាមួយដែលបានធ្វើឡើងតាមកថាខណ្ឌ(១) អាចជាកម្មវត្ថុនៃការបង់កម្រៃ ។

៤- [ ការចុះផ្សាយ ] ការិយាល័យអន្តរជាតិត្រូវចុះផ្សាយសេចក្តីជូនដំណឹង អំពីការកត់ត្រាណាមួយដែលបានធ្វើឡើងតាមកថាខណ្ឌ(១) ។ ការិយាល័យអន្តរជាតិត្រូវផ្ញើឯកសារនៃការចុះផ្សាយសេចក្តីជូនដំណឹង ទៅកាន់ការិយាល័យរបស់ភាគីហត្ថលេខីពាក់ព័ន្ធនីមួយៗផងដែរ ។

## មាត្រា ១៧
## រយៈពេលដំបូង និងការចុះបញ្ជីអន្តរជាតិសារឡើងវិញ និងរយៈពេលនៃកិច្ចការពារ

១- [ រយៈពេលដំបូងនៃការចុះបញ្ជីអន្តរជាតិ ] ការចុះបញ្ជីអន្តរជាតិត្រូវមានសុពលភាពក្នុងរយៈពេល ប្រាំ(៥) ឆ្នាំដំបូង គិតចាប់ពីកាលបរិច្ឆេទចុះបញ្ជីអន្តរជាតិ ។

២- [ ការចុះបញ្ជីអន្តរជាតិសារឡើងវិញ ] ការចុះបញ្ជីអន្តរជាតិអាចធ្វើសារឡើងវិញបានក្នុងរយៈពេលបន្ថែមប្រាំ(៥)ឆ្នាំ ដោយស្របតាមនីតិវិធី ហើយត្រូវបង់កម្រៃដែលបានកំណត់ ។

៣- [ រយៈពេលនៃកិច្ចការពារនៅក្នុងភាគីហត្ថលេខីជ្រើសរើស ]

ក- រយៈពេលនៃកិច្ចការពារនៅក្នុងភាគីហត្ថលេខីជ្រើសរើសនីមួយៗ ត្រូវមានរយៈពេលដប់ប្រាំ(១៥)ឆ្នាំគិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីអន្តរជាតិ ឱ្យតែការចុះបញ្ជីអន្តរជាតិត្រូវបានធ្វើសារឡើងវិញ និងលើកលែងតែអនុកថាខណ្ឌ(ខ) ។

ខ- នៅពេលច្បាប់របស់ភាគីហត្ថលេខីជ្រើសរើសចែងរយៈពេលកិច្ចការពារ ច្រើនជាងដប់ប្រាំ(១៥)ឆ្នាំ ចំពោះគំនូរឧស្សាហកម្ម ដែលកិច្ចការពារនោះត្រូវបានផ្តល់ឱ្យតាមច្បាប់របស់ភាគីហត្ថលេខីជ្រើសរើស រយៈពេលនៃកិច្ចការពារនេះត្រូវមានដូចគ្នាទៅនឹងរយៈពេលដែលច្បាប់របស់ភាគីហត្ថលេខីបានចែង ឱ្យតែមានការចុះបញ្ជីអន្តរជាតិសារឡើងវិញ ។

គ- ភាគីហត្ថលេខីជ្រើសរើសនីមួយៗ ត្រូវជូនដំណឹងទៅអគ្គនាយកតាមរយៈសេចក្តីប្រកាសអំពីរយៈពេលអតិបរមានៃកិច្ចការពារ ដែលច្បាប់របស់ភាគីហត្ថលេខីបានចែង។

៤- [ លទ្ធភាពនៃការចុះបញ្ជីសារឡើងវិញដែលមានកម្រិត ] អាចធ្វើការចុះបញ្ជីអន្តរជាតិសារឡើងវិញចំពោះភាគីហត្ថលេខីជ្រើសរើសណាមួយ ឬទាំងអស់ និងចំពោះគំនូរឧស្សាហកម្មណាមួយ ឬទាំងអស់ដែលជាកម្មវត្ថុនៃការចុះបញ្ជីអន្តរជាតិ ។

៥- [ ការកត់ត្រា និងការចុះផ្សាយនៃការចុះបញ្ជីសារឡើងវិញ ] ការិយាល័យអន្តរជាតិត្រូវកត់ត្រាការចុះបញ្ជីសារឡើងវិញក្នុងបញ្ជីអន្តរជាតិ និងត្រូវចុះផ្សាយសេចក្តីជូនដំណឹងអំពីអានុភាពនៃការចុះបញ្ជី ។ ការិយាល័យអន្តរជាតិត្រូវផ្ញើច្បាប់ចម្លងនៃការចុះផ្សាយសេចក្តីជូនដំណឹងទៅកាន់ការិយាល័យរបស់ភាគីហត្ថលេខីនីមួយៗដែលពាក់ព័ន្ធ។

## មាត្រា១៨
## ពត៌មានស្តីអំពីការចុះផ្សាយការចុះបញ្ជីអន្តរជាតិ

១- [ ការទទួលបាននូវពត៌មាន ] ការិយាល័យអន្តរជាតិត្រូវផ្តល់ឱ្យបុគ្គលណាម្នាក់ដែលបានស្នើសុំនូវសម្រង់ចេញពីបញ្ជីអន្តរជាតិ ឬ ពត៌មានស្តីអំពីខ្លឹមសារនៃបញ្ជីអន្តរជាតិចំពោះការចុះបញ្ជីអន្តរជាតិណាមួយដែលបានចុះផ្សាយ ដោយត្រូវបង់កម្រៃតាមការកំណត់ ។
២- [ ការលើកលែងចំពោះការបញ្ជាក់តាមច្បាប់ ] សម្រង់ចេញពីបញ្ជីអន្តរជាតិដែលបានផ្តល់ឱ្យដោយការិយាល័យអន្តរជាតិ ត្រូវលើកលែងពីលក្ខខណ្ឌណាមួយនៃការបញ្ជាក់ក្នុងភាគីហត្ថលេខីនីមួយ ៗ ។

## ជំពូកទី២
## បទប្បញ្ញត្តិរដ្ឋបាល
## មាត្រា ១៩
## ការិយាល័យរួមនៃរដ្ឋមួយចំនួន

១- [ សេចក្តីជូនដំណឹងអំពីការិយាល័យរួម ] ប្រសិនបើរដ្ឋមួយចំនួនដែលមានបំណងក្លាយជាភាគីនៃច្បាប់នេះបានបង្រួបបង្រួម ឬប្រសិនបើរដ្ឋមួយចំនួនដែលជាភាគីនៃច្បាប់នេះយល់ព្រមបង្រួបបង្រួមច្បាប់ក្នុងស្រុករបស់ខ្លួនដែលទាក់ទងនឹងគំនូរឧស្សាហកម្ម រដ្ឋទាំងនេះអាចជូនដំណឹងទៅអគ្គនាយកថា:

(i) ការិយាល័យរួមត្រូវជំនួសឱ្យការិយាល័យជាតិនីមួយៗ ហើយ

(ii) ដែនដីទាំងមូលនៃរដ្ឋរៀងៗខ្លួន ដែលអនុវត្តច្បាប់ដែលបានបង្រួបបង្រួម ត្រូវចាត់ទុកថាជាភាគីហត្ថលេខីតែមួយ សម្រាប់គោលបំណងនៃការអនុវត្ត មាត្រា(១) មាត្រា(៣) ដល់មាត្រា(១៨) និងមាត្រា(៣១) នៃច្បាប់នេះ ។

២- [ រយៈពេលដែលត្រូវធ្វើសេចក្តីជូនដំណឹង ] សេចក្តីជូនដំណឹងដូចមានចែងក្នុងកថាខណ្ឌ (១) ត្រូវបានធ្វើឡើង:

(i) នៅពេលតម្កល់លិខិតតុបករណ៍ដូចមានចែងក្នុងមាត្រា២៧(២) ក្នុងករណីដែលរដ្ឋណាមួយមានបំណងចង់ក្លាយជាភាគីនៃច្បាប់នេះ ។

(ii) នៅពេលណាមួយបន្ទាប់ពីធ្វើការបង្រួបបង្រួមច្បាប់ក្នុងស្រុករបស់ខ្លួន ក្នុងករណីដែលរដ្ឋណាមួយជាភាគីនៃច្បាប់នេះ។

៣- [ កាលបរិច្ឆេទចូលជាធរមាននៃសេចក្តីជូនដំណឹង ] សេចក្តីជូនដំណឹងដូចមានចែងក្នុងកថាខណ្ឌ(១) និង (២) ត្រូវមានអានុភាព:

(i) នៅពេលដែលរដ្ឋណាមួយបានចងភ្ជាប់ដោយច្បាប់នេះ ក្នុងករណីរដ្ឋនេះមានបំណងក្លាយជាភាគីនៃច្បាប់នេះ

(ii) ក្នុងរយៈបីខែបន្ទាប់ពីកាលបរិច្ឆេទ នៃការជូនដំណឹងដោយអគ្គនាយកទៅកាន់ភាគីហត្ថលេខីផ្សេងទៀត ឬនៅកាលបរិច្ឆេទក្រោយទៀតដូចបានកំណត់ក្នុងសេចក្តីជូនដំណឹងក្នុងករណីរដ្ឋណាមួយជាភាគីនៃច្បាប់នេះ។

## មាត្រា២០
## សមាជិកភាពនៃសហភាពឡាអេ

ភាគីហត្ថលេខីទាំងឡាយ ត្រូវតែជាសមាជិកនៃសហភាពតែមួយដូចទៅនឹងរដ្ឋដែលជាភាគីនៃច្បាប់ឆ្នាំ ១៩៣៤ ឬច្បាប់ឆ្នាំ ១៩៦០ ។

## មាត្រា២១
## សន្និបាត

១- [ សមាសភាព ]

ក-ភាគីហត្ថលេខីទាំងឡាយត្រូវតែជាសមាជិកនៃសន្និបាតតែមួយ ដូចទៅនឹងរដ្ឋដែលត្រូវបានចងភ្ជាប់ដោយមាត្រា២នៃច្បាប់បំពេញបន្ថែមឆ្នាំ ១៩៦៧ ។

ខ- សមាជិកនីមួយៗនៃសន្និបាតត្រូវតំណាងក្នុងសន្និបាតដោយប្រតិភូមួយរូបដែលអាចអមដោយប្រតិភូស្តីទី ទីប្រឹក្សា និងអ្នកជំនាញមួយចំនួន ហើយប្រតិភូម្នាក់ៗអាចតំណាងឱ្យភាគីហត្ថលេខីតែមួយប៉ុនោះ ។

គ- សមាជិកនៃសហភាព ដែលមិនមែនជាសមាជិកនៃសន្និបាតត្រូវបានអនុញ្ញាតឱ្យចូលរួមប្រជុំក្នុងសន្និបាតក្នុងឋានៈជាអ្នកសង្កេតការណ៍ ។

២- [ កិច្ចការ ]

ក-សន្និបាតត្រូវ:

(i) ពិភាក្សារាល់បញ្ហាទាំងអស់ដែលទាក់ទងនឹងការរក្សា និងការអភិវឌ្ឍន៍នៃសហភាព និងការអនុវត្តន៍ច្បាប់នេះ ។

(ii) អនុវត្តសិទ្ធិ និងបំពេញកិច្ចការដែលបានផ្តល់ជាពិសេសឱ្យសន្និបាត ឬផ្ទេរសិទ្ធិនិងកិច្ចការទៅឱ្យសន្និបាតតាមច្បាប់នេះ ឬច្បាប់បំពេញបន្ថែមឆ្នាំ១៩៦៧ ។

(iii) ណែនាំអគ្គនាយកអំពីការរៀបចំសន្និសីទកែប្រែ និងសម្រេចអំពីការកោះប្រជុំសន្និសីទណាមួយ ។

(iv) វិសោធនកម្មបទបញ្ជា ។

(v) ពិនិត្យនិងអនុម័តរបាយការណ៍ និងសកម្មភាពរបស់អគ្គនាយក ទាក់ទងនឹងសហភាព ហើយណែនាំតាមការចាំបាច់ដល់អគ្គនាយក ទាក់ទងនឹងបញ្ហាទាំងឡាយនៃសមត្ថកិច្ចរបស់សហភាព ។

(vi) កំណត់កម្មវិធីនិងអនុម័តថវិការពីរឆ្នាំម្តងនៃសហភាព និងអនុម័តការបិទបញ្ជីគណនី ។

(vii) អនុម័តបទបញ្ជាស្តីពីហិរញ្ញវត្ថុរបស់សហភាព ។

(viii) បង្កើតគណៈកម្មាធិការ និងក្រុមការងារដែលចាំបាច់ដើម្បីសម្រេចគោលបំណងរបស់សហភាព ។

(ix) លើកលែងកថាខណ្ឌ (១) (គ) កំណត់ថារដ្ឋណា អង្គការអន្តររដ្ឋាភិបាលណា និងអង្គការក្រៅរដ្ឋាភិបាលណាដែលត្រូវបានអនុញ្ញាតឱ្យចូលរួម ប្រជុំនៃសន្និបាតក្នុងឋានៈជាអ្នកសង្កេតការណ៍ ។

(x) ចាត់វិធានការសមស្របផ្សេងទៀត ដើម្បីសម្រេចគោលបំណងរបស់សហភាព និងបំពេញមុខងារផ្សេងទៀតដែលស្របតាមច្បាប់នេះ ។

ខ- ចំពោះបញ្ហាដែលពាក់ព័ន្ធនឹងផលប្រយោជន៍ផងដែររបស់សហភាពផ្សេងទៀតដែលគ្រប់គ្រងដោយអង្គការ សន្និបាតត្រូវធ្វើការសម្រេចបន្ទាប់ពីបានស្តាប់យោបល់របស់គណៈកម្មាធិការសម្របសម្រួលនៃអង្គការ ។

៣- [ កូរ៉ុម ]

ក-ចំនួនពាក់កណ្តាលនៃសមាជិករបស់សន្និបាតដែលជារដ្ឋ ហើយមានសិទ្ធិក្នុងការបោះឆ្នោតលើបញ្ហាណាមួយ ត្រូវចាត់ទុកជាកូរ៉ុម សម្រាប់គោលបំណងនៃការបោះឆ្នោតលើបញ្ហានោះ ។

ខ-ថ្វីបើមានចែងក្នុងអនុកថាខណ្ឌ(ក)ក៏ដោយ ក្នុងសម័យប្រជុំនីមួយៗ ប្រសិនបើចំនួននៃសមាជិករបស់សន្និបាត ដែលជារដ្ឋហើយមានសិទ្ធិក្នុងការបោះឆ្នោតលើបញ្ហាណាមួយ ហើយរដ្ឋដែលជាតំណាងមានតិចជាងមួយភាគពីរ(១/២) ប៉ុន្តែស្មើឬច្រើនជាងមួយភាគបី(១/៣) នៃសមាជិករបស់សន្និបាតដែលជារដ្ឋ ហើយមានសិទ្ធិក្នុងការបោះឆ្នោតលើបញ្ហានោះ សន្និបាតអាចធ្វើសេចក្តីសម្រេចបាន ប៉ុន្តែសេចក្តីសម្រេចទាំងនេះត្រូវយកមកអនុវត្តបានតែក្នុងករណីបានបំពេញលក្ខខណ្ឌកំណត់ដូចខាងក្រោម លើកលែង

តែសេចក្ដីសម្រេចនោះទាក់ទងនឹងនីតិវិធីរបស់សន្និបាត ។ ការិយាល័យអន្តរជាតិត្រូវជូនដំណឹងអំពីសេចក្ដីសម្រេចនេះ ទៅសមាជិកទាំងឡាយរបស់សន្និបាតដែលជារដ្ឋហើយមានសិទ្ធិក្នុងការបោះឆ្នោតលើបញ្ហាខាងលើ ដែលគ្មានវត្តមាននិងត្រូវអញ្ជើញប្រទេសទាំងនេះឱ្យបោះឆ្នោតជាលាយលក្ខណ៍អក្សរ ឬបោះឆ្នោតអនុប្បវាទ ក្នុងរយៈពេលបី(៣)ខែ ចាប់ពីថ្ងៃជូនដំណឹង ។ បើផុតរយៈពេលនេះ ប្រសិនបើចំនួននៃសមាជិកដែលបានបោះឆ្នោត ឬបោះឆ្នោតអនុប្បវាទស្មើនឹងចំនួនសមាជិកដែលខ្វះសម្រាប់កូរ៉ុមក្នុងសម័យប្រជុំ សេចក្ដីសម្រេចនេះនឹងអាចយកមកអនុវត្តបាន ឱ្យតែបានគ្រប់សំលេងភាគច្រើនដែលត្រូវការ ។

៤- [ ការសម្រេចក្នុងសន្និបាត ]

ក- សន្និបាតត្រូវខិតខំធ្វើការសម្រេចដោយឯកច្ឆន្ទ ។

ខ- ប្រសិនបើសេចក្ដីសម្រេចមិនបានទទួលសម្លេងឯកច្ឆន្ទ បញ្ហានេះត្រូវសម្រេចដោយការបោះឆ្នោត ។ ក្នុងករណីនេះ :

(i) ភាគីហត្ថលេខីនីមួយៗដែលជារដ្ឋត្រូវមានសំលេងឆ្នោតមួយ ហើយត្រូវបោះឆ្នោតតែក្នុងនាមខ្លួនឯងផ្ទាល់ប៉ុនោះ ហើយ

(ii) ភាគីហត្ថលេខីណាមួយ ដែលជាអង្គការអន្តររដ្ឋាភិបាលអាចបោះឆ្នោតជំនួសសមាជិករបស់ខ្លួនបាន ដោយមានចំនួនសំលេងឆ្នោតស្មើនឹងចំនួនរដ្ឋដែលជាសមាជិករបស់ខ្លួនដែលជាភាគីនៃច្បាប់នេះ ។ អង្គការអន្តររដ្ឋាភិបាល មិនត្រូវចូលរួមនៅក្នុងការបោះឆ្នោត ប្រសិនបើរដ្ឋសមាជិកណាមួយអនុវត្តសិទ្ធិបោះឆ្នោតរបស់ខ្លួន ហើយប្រសិនបើរដ្ឋជាសមាជិកណាមួយ មិនអនុវត្តសិទ្ធិក្នុងការបោះឆ្នោតរបស់ខ្លួននោះអង្គការអន្តររដ្ឋាភិបាលនេះត្រូវចូលរួមក្នុងការបោះឆ្នោត។

គ- ចំពោះបញ្ហាទាក់ទងតែរដ្ឋ ដែលបានចងភ្ជាប់ដោយមាត្រា២ នៃច្បាប់បំពេញបន្ថែមឆ្នាំ១៩៦៧ ភាគីហត្ថលេខីទាំងឡាយដែលមិនបានចងភ្ជាប់ដោយមាត្រានេះមិនមានសិទ្ធិបោះឆ្នោតទេ ចំនែកឯបញ្ហាដែលទាក់ទងតែភាគីហត្ថលេខី មានតែភាគីហត្ថលេខីទេទើបមានសិទ្ធិបោះឆ្នោត ។

៥- [ សំលេងភាគច្រើន ]

ក-លើកលែងមាត្រា ២៤(២) និង ២៦(២) ការសម្រេចរបស់សន្និបាតត្រូវមានសំលេងពីរភាគបី(២/៣) នៃសំលេងឆ្នោតដែលបានបោះ ។

ខ- អនុប្បវាទ មិនត្រូវចាត់ទុកជាសំលេងឆ្នោតទេ ។

៦- [ សម័យប្រជុំ ]

ក- សន្និបាតត្រូវប្រជុំជាសាមញ្ញរៀងរាល់ពីរឆ្នាំម្តង តាមការកោះប្រជុំរបស់អគ្គនាយក ហើយបើគ្មានករណីពិសេស ត្រូវប្រជុំក្នុងពេលនិងកន្លែងដូចគ្នានឹងមហាសន្និបាតរបស់អង្គការ ។

ខ- តាមសំណើសុំពីសមាជិកនៃសន្និបាតមួយភាគបួន(១/៤) ឬ តាមគំនិតផ្តួចផ្តើមផ្ទាល់របស់អគ្គនាយក សន្និបាតត្រូវប្រជុំជាវិសាមញ្ញ តាមការកោះប្រជុំរបស់អគ្គនាយក ។

គ- របៀបវារៈនៃកិច្ចប្រជុំនីមួយៗត្រូវរៀបចំដោយអគ្គនាយក ។

៧- [ បទបញ្ជាផ្ទៃក្នុង ] សន្និបាតត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនដោយផ្ទាល់ ។

## មាត្រា២២
## ការិយាល័យអន្តរជាតិ

១- [ កិច្ចការរដ្ឋបាល ]

ក- ការចុះបញ្ជីអន្តរជាតិ និងកាតព្វកិច្ចដែលពាក់ព័ន្ធ ក៏ដូចជាកិច្ចការរដ្ឋបាលផ្សេងទៀតស្តីអំពីសហភាព ត្រូវបំពេញដោយការិយាល័យអន្តរជាតិ ។

ខ- ជាពិសេស ការិយាល័យអន្តរជាតិត្រូវរៀបចំការប្រជុំ និងត្រូវបំរើការងារជាលេខាធិការដ្ឋានរបស់សន្និបាត និងរបស់គណៈកម្មាធិការជំនាញ និងក្រុមការងារដែលអាចបង្កើតឡើងដោយសន្និបាត ។

២- [អគ្គនាយក ] អគ្គនាយកត្រូវជានាយកប្រតិបត្តិនៃសហភាព និងជាតំណាងសហភាព។

៣-[ កិច្ចប្រជុំក្រៅពីសម័យប្រជុំនៃសន្និបាត ] អគ្គនាយកត្រូវកោះប្រជុំគណៈកម្មាធិការ និងក្រុមការងារដែលបង្កើតដោយសន្និបាត និងកិច្ចប្រជុំផ្សេងៗទៀតដើម្បីដោះស្រាយបញ្ហាដែលទាក់ទងនឹងសហភាព ។

៤- [ តួនាទីនៃការិយាល័យអន្តរជាតិនៅក្នុងសន្និបាតនិងក្នុងកិច្ចប្រជុំផ្សេងទៀត ]

ក- អគ្គនាយកនិងបុគ្គលដែលបានចាត់តាំងដោយអគ្គនាយក ត្រូវចូលរួមគ្រប់កិច្ចប្រជុំរបស់សន្និបាតនិងរបស់គណៈកម្មាធិការ និងក្រុមការងារដែលបានបង្កើតដោយសន្និបាតនិងក្នុងកិច្ចប្រជុំផ្សេងទៀត ដែលបានកោះប្រជុំដោយអគ្គនាយកក្រោមការគាំទ្ររបស់សហភាព តែគ្មានសិទ្ធិនៅក្នុងការបោះឆ្នោតទេ។

ខ- អគ្គនាយក ឬបុគ្គលិកណាម្នាក់ដែលបានចាត់តាំងដោយអគ្គនាយក គឺជាលេខាដោយស្វ័យប្រវត្តិនៃសន្និបាត នៃគណៈកម្មាធិការ និងក្រុមការងារ និង កិច្ចប្រជុំផ្សេងទៀតដូចមានចែងក្នុងអនុកថាខណ្ឌ(ក) ។

៥- [ សន្និសីទ ]

ក- តាមសេចក្តីណែនាំរបស់សន្និបាត ការិយាល័យអន្តរជាតិត្រូវរៀបចំសន្និសីទកែប្រែ ។

ខ- ការិយាល័យអន្តរជាតិអាចប្រឹក្សាជាមួយអង្គការអន្តររដ្ឋាភិបាល និងអង្គការជាតិ និងអន្តរជាតិមិនមែនរដ្ឋាភិបាល ពាក់ព័ន្ធនឹងការរៀបចំសន្និសីទកែប្រែនេះ ។

គ-អគ្គនាយក និងបុគ្គលដែលបានចាត់តាំងដោយអគ្គនាយក ត្រូវចូលរួមក្នុងកិច្ចពិភាក្សាក្នុងសន្និសីទកែប្រែ តែគ្មានសិទ្ធិបោះឆ្នោតទេ ។

៦- [ កិច្ចការផ្សេងទៀត ] ការិយាល័យអន្តរជាតិត្រូវអនុវត្តកិច្ចការផ្សេងទៀត ដែលប្រគល់ឱ្យខ្លួនទាក់ទងនឹងច្បាប់នេះ ។

## មាត្រា២៣
## ហិរញ្ញវត្ថុ

១- [ ថវិកា ]

ក- សហភាពត្រូវមានថវិការបស់ខ្លួន ។

ខ- ថវិការបស់សហភាពរួមមានខ្ទង់ចំនូល និងខ្ទង់ចំណាយផ្ទាល់របស់សហភាព និងវិភាគទានចំពោះថវិកាសម្រាប់ការចំណាយរួមរបស់សហភាព ដែលគ្រប់គ្រងដោយអង្គការ ។

គ- ការចំណាយដែលមិនមែនជាចំណាយផ្តាច់មុខរបស់សហភាព ប៉ុន្តែជាការចំណាយរបស់សហភាពមួយឬច្រើនផ្សេងទៀត ដែលស្ថិតក្រោមការគ្រប់គ្រងរបស់អង្គការ ត្រូវចាត់ទុកជាចំណាយរួមរបស់សហភាព ។ ចំណែកនៃសហភាពក្នុងខ្ទង់ចំណាយរួមនេះ ត្រូវសមាមាត្រនឹងផលប្រយោជន៍ដែលសហភាពទទួលបានក្នុងចំណាយនោះ ។

២- [ ការសម្របសម្រួលជាមួយថវិកានៃសហភាពផ្សេងទៀត ] ថវិការបស់សហភាពត្រូវបង្កើតឡើង ដោយផ្អែកលើតម្រូវការសម្របសម្រួលជាមួយថវិកានៃសហភាពផ្សេងទៀត ដែលគ្រប់គ្រងដោយអង្គការ ។

៣- [ ប្រភពហិរញ្ញប្បទានថវិកា ] ថវិការបស់សហភាពទទួលបានពីប្រភពនានាដូចខាងក្រោម:

- (i) កម្រៃទាក់ទងនឹងការចុះបញ្ជីអន្តរជាតិ
- (ii) ថ្លៃឈ្នួលសេវាកម្មដែលផ្តល់ឱ្យដោយការិយាល័យអន្តរជាតិទាក់ទងនឹងសហភាព
- (iii) ការលក់ ឬលាភការ ពីការចុះផ្សាយរបស់ការិយាល័យអន្តរជាតិពាក់ព័ន្ធនឹងសហភាព

(iv) អំណោយ អច្ច័យទាន និងឧបត្ថម្ភធន

(v) ការជួល ការប្រាក់ និងចំនួលផ្សេងៗទៀត ។

៤- [ការកំណត់កម្រៃនិងថ្លៃឈ្នួល, កម្រិតនៃថវិកា ]

ក-បរិមាណកម្រៃដូចមានចែងក្នុងកថាខណ្ឌ(៣)(i) ត្រូវកំណត់ដោយសន្និបាតតាមសំណើរបស់អគ្គនាយក ។ ថ្លៃឈ្នួល ដូចមានចែងក្នុងកថាខណ្ឌ(៣)(ii) ត្រូវបង្កើតឡើងដោយអគ្គនាយកនិងត្រូវអនុវត្តជាបណ្តោះអាសន្ន តាមការអនុម័តរបស់សន្និបាតនាកិច្ចប្រជុំក្រោយទៀត ។

ខ- បរិមាណកម្រៃដូចមានចែងក្នុងកថាខណ្ឌ(៣)(i) ត្រូវកំនត់ថាចំណូលរបស់សហភាពដែលបានពីកម្រៃនិងប្រភពផ្សេងៗ ត្រូវគ្រប់គ្រាន់ក្នុងការគ្រប់គ្រងលើការចំណាយរបស់ការិយាល័យអន្តរជាតិដែលពាក់ព័ន្ធនឹងសហភាព ។

គ- ប្រសិនបើថវិកាមិនត្រូវបានអនុម័តមុនការចាប់ផ្តើមនៃរយៈពេលហិរញ្ញវត្ថុថ្មីទេ ថវិកានោះត្រូវតែចាត់ទុកថាមានកម្រិតស្មើគ្នាទៅនឹងថវិកាឆ្នាំមុន ដូចមានចែងក្នុងបទបញ្ញាហិរញ្ញវត្ថុ ។

៥- [ មូលនិធិទុនបង្វិល ] សហភាពត្រូវមានមូលនិធិទុនបង្វិលដែលទទួលបានពីចំណូលអាជីវកម្មដែលលើស ប្រសិនបើចំនួនដែលលើសនោះមិនគ្រប់គ្រាន់ និងទទួលបានពីការបង់ប្រាក់សរុបរួមតែមួយពីប្រទេសនីមួយៗនៃសហភាព ។ ប្រសិនបើមូលនិធិនេះមិនគ្រប់គ្រាន់ សន្និបាតត្រូវសម្រេចបង្កើនមូលនិធិនេះ ។ សមាមាត្រ និងលក្ខខណ្ឌនៃការបង់កម្រៃត្រូវកំណត់ដោយសន្និបាតតាមសំណើរបស់អគ្គនាយក ។

៦-[ ប្រាក់បង់មុនដោយរដ្ឋម្ចាស់ផ្ទះ ]

ក- នៅក្នុងកិច្ចព្រមព្រៀងទីស្នាក់ការ ដែលបានចុះជាមួយរដ្ឋដែលអង្គការដាក់ទីស្នាក់ការនៅលើទឹកដីរដ្ឋនោះ ត្រូវចែងថានៅពេលណាដែលមូនិធិទុនបង្វិលមិនគ្រប់គ្រាន់ រដ្ឋនោះត្រូវបង់ប្រាក់ជាមុន ។ ចំនួននៃប្រាក់បង់ជាមុន និងលក្ខខណ្ឌនៃការបង់ជាមុនត្រូវកំណត់ដោយកិច្ចព្រមព្រៀងដោយឡែកពីគ្នារវាងប្រទេសនោះនឹងអង្គការ ។

ខ- រដ្ឋដូចមានចែងក្នុងអនុកថាខណ្ឌ(ក) និងអង្គការ ត្រូវមានសិទ្ធិបដិសេធកាតព្វកិច្ចបង់ប្រាក់ជាមុន ដោយជូនដំណឹងជាលាយលក្ខណ៍អក្សរ ។ ការបដិសេធនេះ ត្រូវមានអានុភាពក្នុងរយៈពេលបី(៣)ឆ្នាំ បន្ទាប់ពីបំណាច់ឆ្នាំនៃការជូនដំណឹង ។

៧-[ សវនកម្មគណនី ] សវនកម្មគណនី ត្រូវធ្វើឡើងដោយរដ្ឋជាសមាជិកមួយ ឬច្រើននៃសហភាព ឬដោយសវនករខាងក្រៅ ដូចមានចែងក្នុងបទបញ្ញាហិរញ្ញវត្ថុ ហើយត្រូវចាត់តាំងដោយសន្និបាតដោយមានការយល់ព្រមពីរដ្ឋ ឬសវនករនេះ ។

## មាត្រា២៤
## បទបញ្ជា

១-[ កម្មវត្ថុ ] បទបញ្ជាត្រូវកំនត់សេចក្តីលំអិតនៃការអនុវត្តច្បាប់នេះ ។ ក្នុងករណីពិសេស បទបញ្ជាត្រូវបញ្ចូលនូវបទប្បញ្ញត្តិពាក់ព័ន្ធនឹង:

(i) បញ្ហានានាដែលច្បាប់នេះបានចែងត្រូវកំណត់ឱ្យបានជាក់លាក់ ។

(ii) សេចក្តីលំអិតបន្ថែមពាក់ព័ន្ធនឹងបទប្បញ្ញត្តិនៃច្បាប់នេះ ឬសេចក្តីលំអិតផ្សេងទៀត ដែលមានប្រយោជន៍ក្នុងការអនុវត្តបទប្បញ្ញត្តិនៃច្បាប់នេះ ។

(iii) លក្ខខណ្ឌរដ្ឋបាល បញ្ហា ឬនីតិវិធីណាមួយ ។

២- [ វិសោធនកម្មនៃមាត្រាមួយចំនួននៃបទបញ្ជា]

ក- បទបញ្ជាអាចបញ្ជាក់នូវបទប្បញ្ញត្តិមួយចំនួននៃបទបញ្ជា អាចត្រូវធ្វើវិសោធនកម្មដោយសម្លេងឯកច្ឆន្ទ ឬ ដោយសម្លេងភាគច្រើនបួនភាគប្រាំ(៤/៥) ។

ខ- ដើម្បីឱ្យលក្ខខណ្ឌនៃសម្លេងឯកច្ឆន្ទ ឬសំលេងភាគច្រើនបួនភាគប្រាំ(៤/៥) លែងអនុវត្តចំពោះវិសោធនកម្មនៃបទប្បញ្ញត្តិនៃបទបញ្ជានាពេលអនាគត ត្រូវទាមទារឱ្យមានសំលេងឯកច្ឆន្ទ ។

គ- ដើម្បីឱ្យលក្ខខណ្ឌនៃសម្លេងឯកច្ឆន្ទ ឬសំលេងភាគច្រើនបួនភាគប្រាំ(៤/៥) អនុវត្តចំពោះវិសោធនកម្មនៃបទប្បញ្ញត្តិនៃបទបញ្ជានាពេលអនាគត ត្រូវទាមទារឱ្យមានសំលេងភាគច្រើនបួនភាគប្រាំ(៤/៥) ។

៣- [ វិវាទរវាងច្បាប់នេះ និងបទបញ្ជា ] ក្នុងករណីដែលមានវិវាទរវាងបទប្បញ្ញត្តិនៃច្បាប់នេះនិងបទប្បញ្ញត្តិនៃបទបញ្ជា បទប្បញ្ញត្តិនៃច្បាប់ត្រូវចាត់ទុកជាបទប្បញ្ញត្តិគោល ។

## ជំពូកទី៣
## ការកែប្រែ និងវិសោធនកម្ម
## មាត្រា២៥
## ការកែប្រែច្បាប់នេះ

១- [ សន្និសីទកែប្រែ ] ច្បាប់នេះអាចកែប្រែដោយសន្និសីទរបស់ភាគីហត្ថលេខី ។

២- [ ការកែប្រែ ឬវិសោធនកម្មមាត្រាមួយចំនួន ] មាត្រា២១ ២២ ២៣ និង ២៦ អាចត្រូវធ្វើវិសោធនកម្មដោយសន្និសីទកែប្រែ ឬដោយសន្និបាត យោងតាមបទប្បញ្ញត្តិនៃមាត្រា ២៦ ។

## មាត្រា២៦
## វិសោធនកម្មមាត្រាមួយចំនួនដោយសន្និបាត

១- [សំណើសុំធ្វើវិសោធនកម្ម ]

ក- សំណើសុំធ្វើវិសោធនកម្មមាត្រា២១ ២២ ២៣ និងមាត្រានេះ ដោយសន្និបាត អាចផ្តួចផ្តើមដោយភាគីហត្ថលេខីណាមួយ ឬដោយអគ្គនាយក ។

ខ- សំណើនេះត្រូវជូនដំណឹងដោយអគ្គនាយក ទៅភាគីហត្ថលេខីទាំងឡាយយ៉ាងហោចណាស់ប្រាំមួយ (៦)ខែ មុនការពិចារណាដោយសន្និបាត ។

២- [ សំលេងភាគច្រើន ] ការអនុម័តវិសោធនកម្មមាត្រាណាមួយ ដូចមានចែងក្នុងកថាខណ្ឌ(១) ត្រូវមានសំលេងភាគច្រើនបីភាគបួន(៣/៤) លើកលែងតែការអនុម័តវិសោធនកម្មមាត្រា២១ ឬកថាខណ្ឌនេះ ត្រូវមានសំលេងភាគច្រើនបួនភាគប្រាំ(៤/៥) ។

៣-[ ការចូលជាធរមាន ]

ក- លើកលែងតែត្រូវអនុវត្តអនុកថាខណ្ឌ(ខ) ការធ្វើវិសោធនកម្មមាត្រាទាំងឡាយដូចមានចែងក្នុងកថាខណ្ឌ(១) ត្រូវចូលជាធរមានមួយ(១)ខែ បន្ទាប់ពីទទួលបានសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរដែលបានធ្វើដោយស្រប តាមដំណើរការរដ្ឋធម្មនុញ្ញរៀងៗខ្លួន ហើយដែលបានទទួលដោយអគ្គនាយក ពីភាគីហត្ថលេខីចំនួនបីភាគបួន (៣/៤) ដែលនៅពេលអនុម័តយកវិសោធនកម្មនេះជាសមាជិកនៃសន្និបាត ហើយមានសិទ្ធិបោះឆ្នោតលើវិសោធនកម្មនេះ ។

ខ- ការធ្វើវិសោធនកម្មណាមួយចំពោះមាត្រា២១(៣) ឬ (៤) ឬអនុកថាខណ្ឌនេះ មិនអាចចូលជាធរមានទេ ប្រសិនបើ ក្នុងរយៈពេលប្រាំមួយ(៦)ខែ នៃការអនុម័តដោយសន្និបាត ភាគីហត្ថលេខីណាមួយបានជូនដំណឹងទៅអគ្គនាយកថាខ្លួនមិនទទួលយកវិសោធនកម្មនេះ ។

គ - ការធ្វើវិសោធនកម្មណាមួយ ដែលចូលជាធរមានស្របតាមបទប្បញ្ញត្តិនៃកថាខណ្ឌនេះ ត្រូវចងភ្ជាប់រដ្ឋនិងអង្គការអន្តរដ្ឋាភិបាលទាំងឡាយដែលជាភាគីហត្ថលេខី នៅពេលដែលវិសោធនកម្មនេះចូលជាធរមាន ឬដែលក្លាយជាភាគីហត្ថលេខី នាកាលបរិច្ឆេទក្រោយ ។

## ជំពូកទី៤
## អវសានបញ្ញត្តិ
## មាត្រា២៧
## ការក្លាយជាភាគីនៃច្បាប់នេះ

១- [ លក្ខខណ្ឌដែលត្រូវបំពេញ ] លើកលែងកថាខណ្ឌ(២) និង (៣) និងមាត្រា ២៨ :

(i) រដ្ឋណាមួយដែលជាសមាជិកនៃអង្គការអាចចុះហត្ថលេខា និងក្លាយជាភាគីនៃច្បាប់នេះ ។

(ii) អង្គការអន្តររដ្ឋាភិបាលណាមួយ ដែលមានការិយាល័យជាអ្នកផ្តល់កិច្ចការពារគំនូរឧស្សាហកម្មដែលមានអានុភាពក្នុងដែនដី ដែលអនុវត្តសន្ធិសញ្ញាបង្កើតអង្គការអន្តររដ្ឋាភិបាល អាចចុះហត្ថលេខានិងក្លាយជាភាគីនៃច្បាប់នេះឱ្យតែយ៉ាងហោចណាស់មានសមាជិកមួយក្នុងចំណោមរដ្ឋ ដែលជាសមាជិកនៃអង្គការអន្តររដ្ឋាភិបាលជាសមាជិកនៃអង្គការនេះ ហើយឱ្យតែការិយាល័យនេះមិនមែនជាកម្មវត្ថុនៃសេចក្តីជូនដំណឹងតាមមាត្រា១៩ ។

២- [ ការផ្តល់សច្ចាប័ន ឬ ការចូលជាសមាជិក ] រដ្ឋ ឬអង្គការអន្តររដ្ឋាភិបាលណាមួយ ដូចមានចែងនៅក្នុងកថាខណ្ឌ(១) អាចតម្កល់នូវ:

(i) លិខិតតុបករណ៍នៃការផ្តល់សច្ចាប័ន ប្រសិនបើរដ្ឋ ឬអង្គការអន្តររដ្ឋាភិបាលបានចុះហត្ថលេខាលើច្បាប់នេះ ឬ

(ii) លិខិតតុបករណ៍នៃការចូលជាសមាជិក ប្រសិនបើរដ្ឋ ឬអង្គការអន្តររដ្ឋាភិបាលមិនបានចុះហត្ថលេខាលើច្បាប់នេះ ។

៣- [ កាលបរិច្ឆេទអានុភាពនៃការតម្កល់ ]

ក- លើកលែងអនុកថាខណ្ឌ(ខ)ដល់(ឃ) កាលបរិច្ឆេទអានុភាពនៃការតម្កល់លិខិតតុបករណ៍នៃការផ្តល់សច្ចាប័ន ឬការចូលជាសមាជិក ត្រូវជាកាលបរិច្ឆេទនៃការតម្កល់លិខិតតុបករណ៍នេះ ។

ខ- កាលបរិច្ឆេទនៃការតម្កល់លិខិតតុបករណ៍នៃការផ្តល់សច្ចាប័ន ឬការចូលជាសមាជិកនៃរដ្ឋណាមួយដែលកិច្ចការពារគំនូរឧស្សាហកម្ម អាចទទួលបានតែតាមរយៈការិយាល័យដែលបានគ្រប់គ្រងដោយអង្គការអន្តររដ្ឋាភិបាល ដែលរដ្ឋនេះជាសមាជិកត្រូវតែជាកាលបរិច្ឆេទ នៃការតម្កល់លិខិតតុបករណ៍របស់អង្គការអន្តររដ្ឋាភិបាលនេះ

ប្រសិនបើកាលបរិច្ឆេទនេះ មានក្រោយកាលបរិច្ឆេទ នៃការតម្កល់លិខិតតុបករណ៍របស់រដ្ឋនេះ ។

គ- កាលបរិច្ឆេទអានុភាព នៃការតម្កល់លិខិតតុបករណ៍នៃការផ្តល់សច្ចាប័ន ឬការចូលជាសមាជិកដែលមាន ឬភ្ជាប់ដោយសេចក្តីជូនដំណឹង ដូចមានចែងក្នុងមាត្រា ១៩ ត្រូវតែជាកាលបរិច្ឆេទនៃការតម្កល់លិខិតតុបករណ៍របស់រដ្ឋទាំងឡាយ ដែលជាសមាជិកនៃក្រុមរដ្ឋ ដែលបានធ្វើសេចក្តីជូនដំណឹងនេះ ។

ឃ- លិខិតតុបករណ៍នៃការផ្តល់សច្ចាប័ន ឬការចូលជាសមាជិកនៃរដ្ឋមួយអាចមាន ឬភ្ជាប់ដោយសេចក្តីប្រកាស ហើយតាមរយៈសេចក្តីប្រកាសនេះ លិខិតតុបករណ៍នេះត្រូវចាត់ទុកថាបានតម្កល់ ប្រសិនបើលិខិតតុបករណ៍នៃរដ្ឋមួយផ្សេងទៀតឬអង្គការអន្តររដ្ឋាភិបាលមួយផ្សេងទៀត ឬលិខិតតុបករណ៍នានារបស់រដ្ឋពីរផ្សេងទៀត ឬលិខិតតុបករណ៍នានារបស់រដ្ឋផ្សេងមួយទៀតនិងអង្គការអន្តររដ្ឋាភិបាលមួយ ដែលមានបញ្ជាក់ឈ្មោះច្បាស់លាស់ ហើយដែលបានបំពេញលក្ខខណ្ឌដើម្បីក្លាយជាភាគីនៃច្បាប់នេះបានតម្កល់ផងដែរ ។ លិខិតុករណ៍ដែលមានឬភ្ជាប់ដោយសេចក្តីប្រកាសនេះ ត្រូវចាត់ទុកថាបានតម្កល់នាថ្ងៃ ដែលបានបំពេញលក្ខខណ្ឌដូចបានកំណត់ នៅក្នុងសេចក្តីប្រកាសនេះ ។ ប៉ុន្តែ នៅពេលដែលលិខិតតុបករណ៍ដែលត្រូវបានបញ្ជាក់ ក្នុងសេចក្តីប្រកាសមានដោយខ្លួនឯងនូវសេចក្តីប្រកាសដែលមានប្រភេទដូចគ្នា ឬភ្ជាប់ដោយសេចក្តីប្រកាសដែលមានប្រភេទដូចគ្នា លិខិតតុបករណ៍នេះត្រូវចាត់ទុកថាបានតម្កល់នៅថ្ងៃដែលបានបំពេញលក្ខខណ្ឌដូចមានកំណត់ ក្នុងសេចក្តីប្រកាសក្រោយ ។

ង- សេចក្តីប្រកាសណាមួយដែលបានធ្វើឡើងក្រោមកថាខណ្ឌ(ឃ) អាចដកវិញទាំងស្រុងឬជាផ្នែកនៅពេលណាក៏បាន ។ ការដកនេះ ត្រូវមានអានុភាពតាមកាលបរិច្ឆេទដែលសេចក្តីជូនដំណឹងនៃការដកនោះ ត្រូវបានទទួលដោយអគ្គនាយក ។

## មាត្រា២៨
## កាលបរិច្ឆេទអានុភាពនៃការផ្តល់សច្ចាប័ន និងការចូលជាសមាជិក

១- [លិខិតតុបករណ៍ដែលត្រូវយកមកពិចារណា ] ជាគោលបំណងនៃមាត្រានេះត្រូវយកមកពិចារណាតែលិខិតតុបករណ៍នៃ ការផ្តល់សច្ចាប័ន ឬការចូលជាសមាជិកណាដែលបានតម្កល់ដោយរដ្ឋ ឬអង្គការអន្តររដ្ឋាភិបាល ដូចមានចែងក្នុងមាត្រា២៧(១) និងដែលមានកាលបរិច្ឆេទអានុភាពតាមមាត្រា២៧(៣) ។

២- [ ការចូលជាធរមាននៃច្បាប់នេះ ] ច្បាប់នេះត្រូវចូលជាធរមានក្នុងរយៈពេលបី(៣) ខែ បន្ទាប់ពីរដ្ឋចំនួនប្រាំមួយ(៦) បានតម្កល់លិខិតតុបករណ៍នៃការផ្តល់សច្ចាប័ន ឬការចូលជាសមាជិក ហើយយោងតាមស្ថិតិថ្មីប្រចាំឆ្នាំ ដែលការិយាល័យអន្តរជាតិប្រមូលបានឱ្យតែយ៉ាងហោចណាស់មានរដ្ឋចំនួនបី(៣) ក្នុងចំណោមរដ្ឋទាំងប្រាំមួយនោះបានបំពេញនូវលក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌដូចខាងក្រោមៈ

(i) យ៉ាងហោចណាស់ មានសំណុំលិខិតស្នើសុំកិច្ចការពារគំនូរឧស្សាហកម្មចំនួនបីពាន់(៣,០០០) បានដាក់ក្នុង ឬក្នុងនាមរដ្ឋដែលពាក់ព័ន្ធ ឬ

(ii) យ៉ាងហោចណាស់ មានសំណុំលិខិតស្នើសុំកិច្ចការពារគំនូរឧស្សាហកម្មចំនួនមួយពាន់(១,០០០) បានដាក់ក្នុង ឬក្នុងនាមរដ្ឋដែលពាក់ព័ន្ធ ដោយពលរដ្ឋផ្សេងពីរដ្ឋនេះ ។

៣- [ ការចូលជាធរមាននៃការផ្តល់សច្ចាប័ន និងការចូលជាសមាជិក ]

ក- រដ្ឋ ឬអង្គការអន្តររដ្ឋាភិបាលណាមួយដែលបានតម្កល់លិខិតតុបករណ៍នៃការផ្តល់សច្ចាប័ន ឬការចូលជាសមាជិកក្នុងរយៈពេលបី(៣)ខែ ឬច្រើនជាងនេះ មុនកាលបរិច្ឆេទចូលជាធរមាននៃច្បាប់នេះ ត្រូវចងភ្ជាប់ដោយច្បាប់នេះតាមកាលបរិច្ឆេទនៃការចូលជាធរមាននៃច្បាប់នេះ។

ខ- រដ្ឋ ឬអង្គការអន្តររដ្ឋាភិបាលណាមួយផ្សេងទៀតត្រូវចងភ្ជាប់ដោយច្បាប់នេះក្នុងរយៈពេលបី(៣)ខែ បន្ទាប់ពីកាលបរិច្ឆេទដែលរដ្ឋ ឬអង្គការអន្តររដ្ឋាភិបាលនោះបានតម្កល់លិខិតតុបករណ៍នៃការផ្តល់សច្ចាប័ន ឬការចូលជាសមាជិក ឬតាមកាលបរិច្ឆេទនាពេលក្រោយទៀតដូចបានកំណត់ក្នុងលិខិតតុបករណ៍នេះ ។

## មាត្រា២៩
## ការហាមឃាត់ចំពោះខដាក់លក្ខខណ្ឌ

ច្បាប់នេះមិនអនុញ្ញាតឱ្យមានខដាក់លក្ខខណ្ឌទ្បើយ ។

## មាត្រា៣០
## សេចក្តីប្រកាសធ្វើឡើងដោយភាគីហត្ថលេខី

១- [ ពេលវេលានៃការធ្វើសេចក្តីប្រកាសន ] សេចក្តីប្រកាសណាមួយតាមមាត្រា៤(១)(ខ) ៥(២)(ក) ៧(២) ១១(១) ១៣(១) ១៥(៣) ១៦(២) ឬ ១៧(៣)(គ) អាចធ្វើឡើងៈ

(i) នៅពេលតម្កល់លិខិតតុបករណ៍ដូចមានចែងក្នុងមាត្រា២៧(២) ក្នុងករណីដែលការតម្កល់មានអានុភាពអនុវត្តតាមកាលបរិច្ឆេទនៃការចងភ្ជាប់ដោយច្បាប់នេះចំពោះរដ្ឋ ឬអង្គការអន្តររដ្ឋាភិបាលដែលបានធ្វើសេចក្តីប្រកាសនេះ ឬ

(ii) បន្ទាប់ពីការតម្កល់លិខិតតុបករណ៍ ដូចមានចែងក្នុងមាត្រា២៧(២) ក្នុងករណីដែលការតម្កល់មានអានុភាពអនុវត្តក្នុងរយៈពេលបី(៣)ខែ បន្ទាប់ពីកាលបរិច្ឆេទដែលអគ្គនាយកបានទទួលលិខិតតុបករណ៍ ឬតាមកាលបរិច្ឆេទនាពេលក្រោយណាមួយទៀតដូចបានកំណត់នៅក្នុងសេចក្តីប្រកាស ប៉ុន្តែត្រូវអនុវត្តត្រឹមតែចំពោះការចុះបញ្ជីអន្តរជាតិណាមួយ ដែលកាលបរិច្ឆេទនៃការចុះបញ្ជីអន្តរជាតិនោះគឺដូចទៅនឹងកាលបរិច្ឆេទអានុភាពនៃសេចក្តីប្រកាស ឬក្រោយកាលបរិច្ឆេទនេះ ។

២-[ សេចក្តីប្រកាសដោយរដ្ឋដែលមានការិយាល័យរួម ] ថ្វីបើមានចែងក្នុងកថាខណ្ឌ(១)ក៏ដោយ សេចក្តីប្រកាសណាមួយដូចមានចែងក្នុងកថាខណ្ឌនោះ ដែលបានធ្វើឡើងដោយរដ្ឋមួយជាមួយរដ្ឋមួយទៀត ឬជាមួយរដ្ឋដទៃទៀតដែលបានជូនដំណឹងទៅអគ្គនាយកតាមមាត្រា១៩(១) អំពីការជំនួសការិយាល័យជាតិ របស់រដ្ឋដោយការិយាល័យរួម ត្រូវមានអានុភាពអនុវត្ត ប្រសិនបើរដ្ឋផ្សេងណាមួយធ្វើសេចក្តីប្រកាសដែលពាក់ព័ន្ធ។

៣- [ ការដកសេចក្តីប្រកាស ] សេចក្តីប្រកាសណាមួយដូចមានចែងក្នុងកថាខណ្ឌ(១) អាចដកនូវពេលណាក៏បានតាមរយៈការជូនដំណឹងទៅកាន់អគ្គនាយក។ ការដកនេះត្រូវចាប់អនុវត្តក្នុងរយៈពេលបី(៣)ខែ បន្ទាប់ពីកាលបរិច្ឆេទដែលអគ្គនាយកបានទទួលសេចក្តីជូនដំណឹង ឬតាមកាលបរិច្ឆេទណាមួយក្រោយទៀតដូចបានកំណត់ក្នុងសេចក្តីជូនដំណឹង ។ នៅក្នុងករណីដែលសេចក្តីប្រកាសបានធ្វើឡើងតាមមាត្រា៧(២) ការដកនេះមិនត្រូវប៉ះពាល់ដល់សំណុំលិខិតស្នើសុំអន្តរជាតិដែលបានដាក់មុនការដកនេះមានអានុភាពអនុវត្ត ។

## មាត្រា៣១
## ការអនុវត្តច្បាប់ឆ្នាំ ១៩៣៤ និងច្បាប់ឆ្នាំ ១៩៦០

១-[ ទំនាក់ទំនងរវាងរដ្ឋជាភាគីទៅនឹងច្បាប់នេះ នឹងច្បាប់ឆ្នាំ ១៩៣៤ ឬ ១៩៦០ ] ច្បាប់នេះតែមួយ អាចអនុវត្តចំពោះទំនាក់ទំនងទៅវិញទៅមកនៃរដ្ឋដែលជាភាគីនៃច្បាប់នេះ និងច្បាប់ឆ្នាំ១៩៣៤ឬ១៩៦០ ។ ប៉ុន្តែ ក្នុងទំនាក់ទំនងទៅវិញទៅមករបស់ខ្លួន រដ្ឋទាំងនេះអនុវត្តច្បាប់ឆ្នាំ១៩៣៤ឬឆ្នាំ១៩៦០ តាមករណីនីមួយៗចំពោះគំនូរឧស្សាហកម្មដែលបានតម្កល់នៅការិយាល័យអន្តរជាតិ មុនកាលបរិច្ឆេទដែលច្បាប់នេះអាចអនុវត្តចំពោះទំនាក់ទំនងទៅវិញទៅមករបស់ប្រទេសទាំងនេះ ។

២- [ ទំនាក់ទំនងរវាងរដ្ឋជាភាគីទៅនឹងច្បាប់នេះ និងច្បាប់ឆ្នាំ១៩៣៤ ឬ ១៩៦០ និងរដ្ឋជាភាគីនៃច្បាប់ឆ្នាំ១៩៣៤ឬ១៩៦០ ដែលមិនមែនជាភាគីនៃច្បាប់នេះ ]

ក- រដ្ឋណាមួយដែលជាភាគីនៃច្បាប់នេះ និងច្បាប់ឆ្នាំ១៩៣៤ ត្រូវបន្តអនុវត្តច្បាប់ឆ្នាំ១៩៣៤ក្នុងទំនាក់ទំនងជាមួយរដ្ឋនានាដែលជាភាគីនៃច្បាប់ឆ្នាំ១៩៣៤ ដែលពុំមែនជាភាគីនៃច្បាប់ឆ្នាំ១៩៦០ ឬច្បាប់នេះ ។

ខ- រដ្ឋណាមួយដែលជាភាគីនៃច្បាប់នេះ និងច្បាប់ឆ្នាំ១៩៦០ ត្រូវបន្តអនុវត្តច្បាប់ឆ្នាំ១៩៦០ ក្នុងទំនាក់ទំនងជាមួយរដ្ឋនានាដែលជាភាគីនៃច្បាប់ឆ្នាំ១៩៦០ ដែលពុំមែនជាភាគីនៃច្បាប់នេះ ។

## មាត្រា៣២
## ការប្រកាសដកខ្លួនចេញពីច្បាប់នេះ

១- [ ការជូនដំណឹង ] ភាគីហត្ថលេខីណាមួយអាចប្រកាសដកខ្លួនចេញពីច្បាប់នេះ ដោយធ្វើការជូនដំណឹងទៅកាន់អគ្គនាយក ។

២- [ កាលបរិច្ឆេទអានុភាព ] ការប្រកាសដកខ្លួនចេញ ត្រូវមានអានុភាពក្នុងរយៈពេលមួយ(១)ឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទដែលអគ្គនាយកបានទទួលនូវសេចក្តីជូនដំណឹង ឬតាមកាលបរិច្ឆេទនាពេលក្រោយណាមួយទៀតដូចបានកំណត់ក្នុងសេចក្តីជូនដំណឹង។ ការប្រកាសដកខ្លួនចេញនេះមិនត្រូវប៉ះពាល់ដល់ការអនុវត្តច្បាប់នេះ ចំពោះសំណុំលិខិតស្នើសុំអន្តរជាតិណាមួយដែលកំពុងព្យួរទុក ព្រមទាំងចំពោះការចុះបញ្ជីអន្តរជាតិណាមួយដែលបានចូលជាធរមានក្នុងដែនដីនៃភាគីហត្ថលេខី ដែលបានប្រកាសដកខ្លួនចេញនៅពេលដែលការប្រកាសដកខ្លួនចេញនេះមានអានុភាពអនុវត្ត ។

## មាត្រា៣៣
## ភាសានៃច្បាប់នេះ ការចុះហត្ថលេខា

១- [ អត្ថបទដើម,អត្ថបទផ្លូវការ ]

ក- ច្បាប់នេះត្រូវចុះហត្ថលេខាជាភាសាដើមតែមួយ គឺជាភាសាអង់គ្លេស ភាសាអារ៉ាប់ ភាសាចិន ភាសាបារាំង ភាសារុស្ស៊ី និងភាសាអេស្ប៉ាញ ។ អត្ថបទទាំងអស់នេះមានតំលៃស្មើៗគ្នា។

ខ- អត្ថបទផ្លូវការនានាត្រូវបង្កើតដោយអគ្គនាយក បន្ទាប់ពីការពិគ្រោះយោបល់ជាមួយរដ្ឋាភិបាលដែលពាក់ព័ន្ធ ជាភាសាផ្សេងទៀតដែលសន្និបាតអាចកំណត់ ។

២- [ រយៈពេលកំណត់ក្នុងការចុះហត្ថលេខា ] ច្បាប់នេះនៅតែបើកចំហសម្រាប់ការចុះហត្ថលេខា នៅទីស្នាក់ការរបស់អង្គការក្នុងរយៈពេលមួយ (១) ឆ្នាំ បន្ទាប់ពីការអនុម័ត ។

## មាត្រា៣៤
## កន្លែងតម្កល់

អគ្គនាយកគឺជាកន្លែងតម្កល់នៃច្បាប់នេះ ។